រឿង

# មហាភារតយុទ្ធ

អ្នកប្រែ

ឧកញ៉ាទេពពិទូរ ឈឹម ក្រសេម

អ្នកពិនិត្យ

ឃុនបណ្ណានុរក្ស ប៊ូ ប៉ូ

ខ្សែទី ១

បោះពុម្ពលើកទី ២

៥០០ ច្បាប់

រក្សាសិទ្ធិ

២៥០៩ - ១៩៦៦

# ពាក្យឧទ្ទេស

រឿងមហាភារតយុទ្ធនេះ ជារឿងចម្បាំងយ៉ាងធំសម្បើមអស្ចារ្យមួយ ប្រហែលគ្នានឹងរឿងរាមកេរ្តិ៍ដែរ ប៉ុន្តែកើតក្រោយរឿងរាមកេរ្តិ៍បន្តិច ជារឿងចាស់បុរាណ ចាប់កំណើតកើតមានឡើងជាដំបូងក្នុងប្រទេសឥណ្ឌា ក្នុងសករាជប៉ុន្មានមិនប្រាកដ ។ ពួកអ្នកប្រទេសឥណ្ឌាចូលចិត្តតំណាលចែកគ្នាស្តាប់ ជាងរឿងរាមកេរ្តិ៍ទៅទៀត ។ ប៉ុន្តែចំពោះកម្ពុជរដ្ឋវិញ រឿងនេះបានកំបាំងបាត់ស្ងាត់ទៅជាយូរឆ្នាំហើយ ព្រោះអ្នកប្រទេសកម្ពុជាសម័យនេះ មិនសូវមានលោកអ្នកណាចេះដឹងចាំរឿងនេះទេ ច្រើនតែចេះដឹងចាំរឿងរាមកេរ្តិ៍វិញ ។ ពីបុរាណសម័យ ប្រជាជនខ្មែរយើងច្រើនចេះដឹងចាំរឿង មហាភារតយុទ្ធយ៉ាងពិតប្រាកដណាស់ រហូតដល់ទៅបានឆ្លាក់ជារូបភាពចម្បាំងរឿងនេះនៅប្រាសាទនគរវត្ត នៅព្រះរបៀងទី ១ ជាន់ខាងលិច ភាគខាងត្បូងផង ។ ខ្ញុំបានមើលឃើញក្បាច់ចម្លាក់រឿងនេះ ក្នុងគ្រាដែលខ្ញុំទៅទទួលភារៈជាអ្នកនាំផ្លូវមើលទីប្រាសាទនគរវត្ត(គ.ស. ១៩២៧) ខ្ញុំក៏ខំប្រឹងស្រាវជ្រាវរកមើលក្បួនតម្រារឿងនេះ ទាល់តែបានចេះដឹងយល់សព្វគ្រប់ ដូចមានសម្តែងតទៅខាងមុខស្រាប់ ។

ឯរឿងមហាភារតយុទ្ធនេះ ក្នុងច្បាប់ដើមបំផុតជាអក្សរសំស្ក្រឹត ជាភាសាសំស្ក្រឹត ដែលគេបានចារិកទុកក្នុងប្រទេសឥណ្ឌាតាំងពីបុរាណសម័យ ។ លុះចំណិរចិរកាលមក អ្នកនានាប្រទេសមាន

ប្រទេសថៃជាដើម បានចម្លងហើយប្រែមកជាភាសារបស់ខ្លួន ។ ការប្រែនោះ គេនៅតែរក្សាសម្ពស្សនៃភាសាសំស្រ្កឹតតាមច្បាប់ដើមដដែល ឥតកែប្រែផ្លាស់ប្តូរទេ ។ ចំពោះរូបខ្ញុំបានប្រែរឿងនេះចេញមកពីច្បាប់ភាសាថៃ ខ្ញុំក៏នៅតែរក្សាសម្ពស្សនៃភាសាសំស្រ្កឹតដូចច្បាប់អក្សរថៃដែរ ព្រោះខ្ញុំមានបំណងឲ្យបច្ឆិមាជនភាជនជាន់ក្រោយដែលជាអ្នកសិក្ខាកាម បានចេះដឹងភាសាសំស្រ្កឹតដែលខ្មែរយើងយកមកប្រើលាយចម្រុះនឹងភាសាបាលីខ្លះ ។ ដូច្នេះ កាលបើលោក-អ្នកបានអានរឿងនេះហើយ ប្រសិនជាមានទើសទាស់ងឿងឆ្ងល់ត្រង់ពាក្យពេចន៍ណាមួយក្នុងផ្ទៃរឿងនេះ សូមលោក-អ្នកសាកថ្លាជាមួយសំស្រ្កឹតវេយ្យាករណ៍បណ្ឌិតចុះ[១] ដើម្បីឱ្យបានចេះដឹងភាសាសំស្រ្កឹត និងបាលីឱ្យច្បាស់ចត់ ដ្បិតក្នុងភាសាខ្មែរយើងសព្វថ្ងៃនេះ ប្រើភាសាបាលី និងសំស្រ្កឹតច្រើនណាស់ តាមពូជពង្សដែលជាប់សែស្រឡាយពីជាតិឥណ្ឌៀមក ។ ប្រសិនបើលោក-អ្នកអានរឿងនេះហើយ មានសេចក្តីសង្ស័យក្នុងពាក្យណាមួយ ហើយចេះតែនៅស្ងៀមឈឹងទៅ មុខជាឥតបានផលប្រយោជន៍ពីការអានរឿងនេះសោះ បានផលតែត្រង់នៅជាអ្នកមិនចេះដឹងប៉ុណ្ណោះ ។

ខ្ញុំយល់ឃើញថា ប្រជាជនខ្មែរយើងសម័យបច្ចុប្បន្ននេះក្តី សម័យអនាគតក្តី ត្រូវតែសង្វាតអានរឿងនេះឱ្យចេះចាំ ប្រហែលខ្មែរ

(១)-អ្នកប្រាជ្ញចេះចាំគោល ឬ មូលរបស់ភាសាសំស្រ្កឹត ។



បុរាណ ទើបនឹងបានផ្សាយអក្សរសាស្រ្តរបស់ប្រទេសជាតិឲ្យសាយភាយទូទៅ ព្រោះរឿងមហាភារតយុទ្ធនេះ ជារឿងចម្បាំងយ៉ាងធំសម្បើមអស្ចារ្យ ប្រហែលជារឿងរាមកេរ្តិ៍ ឬក៏រឿងសាមកុករបស់ចិន ព្រោះមានទាំងនយោបាយកលសឹក មានទាំងយុទ្ធសាស្រ្តជាច្រើនប្រការក្នុងផ្ទៃនៃរឿងនេះ ។

នៅទីបំផុតខ្ញុំសូមអភ័យទោស អំពីសំណាក់អស់លោកអ្នកប្រាជ្ញកវីនិពន្ធខ្មែរ សូមកុំញញើតក្នុងចិត្តចំពោះរឿងនេះឡើយ បើមើលឃើញត្រង់ណា ឬពាក្យណាលើសលស់ខុសឆ្គាំឆ្គង សូមមេត្តាកែតម្រូវសេចក្តី ឬពាក្យនោះឲ្យទានផង ដ្បិតជាធម្មតាអ្នកប្រែពីភាសាមួយទៅភាសាមួយ កម្រនឹងរកពាក្យឱ្យបានត្រូវត្រង់គ្នាណាស់ តោងតែប្រែផ្សំសម្រួលទៅតាមប្រយោគសេចក្តីផង ។ ការភ្លាត់ខុសជាធម្មតារបស់អ្នកនិពន្ធ ដូចសុភាសិតខ្មែរបុរាណថា «សត្វជើងបួនគង់មានភ្លាត់, ប្រាជ្ញចេះស្ទាត់គង់មានភ្លេច» មានតែអ្នកនៅស្ងៀមឥតធ្វើអីសោះនោះទេ ទើបគ្មានការទាស់ខុសឡើយ ។

ហេតុនេះសូមមេត្តាអភ័យទោសដល់ខ្ញុំ ។

ភ្នំពេញនៅថ្ងៃទី ២០ ខែមករា ព. ស. ២ ៤៩៧ គ. ស. ១៩៥៥

អ្នកប្រែ ឧកញ៉ាទេពពិទូរ **ឈឹម ក្រសេម**

## យោបល់របស់អ្នកសរសេរ

រឿងនេះ ខ្ញុំយល់ថាជារឿងគួរតែលោក-អ្នកអានកុំខាន ព្រោះនឹងធ្វើប្រយោជន៍ឲ្យកើតដល់លោកអ្នកជាច្រើនប្រការ គឺ៖

១-ឲ្យដឹងថា ខ្លួនយើងយល់អក្សរសាស្រ្តខ្មែរច្បាស់លាស់ហើយឬនៅឡើយទេ ដោយយើងមានរឿងនេះមិនបាច់សាកសួរលោក-អ្នកណា គឺថាយល់ពាក្យពេចន៍គ្រប់មាត់ ព្រមទាំងស្តាប់សេចក្តីដោយចំណេះរបស់ខ្លួន ។ល។

២- រឿងនេះចង្អុលឱ្យឃើញគតិលោកធម៌ដូចម្តេច ?

រឿងនេះ ជាជញ្ជីងថ្លឹងចំណេះវិជ្ជាអក្សរសាស្រ្តខ្មែរ ជាថ្នាំកែរោគល្ងង់ក្នុងអក្សរសាស្រ្តខ្មែរ ប៉ុន្តែជាពិសពុលដល់អ្នកឥតគំនិតអំពីអក្សរសាស្រ្តខ្មែរ ។ រឿងនេះប្រៀបដូចឈើស្លែងដងដឹងដែលគេបរិភោគផ្លែវានឹងពុលដល់ស្លាប់ ប៉ុន្តែចំពោះគ្រូពេទ្យអ្នកពូកែ អាចយកផ្លែស្លែងនោះ មកធ្វើជាថ្នាំរម្ងាប់រោគផ្សេង ៗ យ៉ាងស័ក្តិសិទ្ធិមានរោគឃ្លង់ជាដើម ។



ហេតុនេះ សូមលោក-អ្នកអាន កុំសម្លឹងយកតែផ្ទៃរឿងប៉ុណ្ណោះ សូមសង្កេតមើលវេយ្យាករណ៍ អក្ខរាវិរុទ្ធ ពាក្យពេចន៍ជាប្រយោជន៍, សំនួនវោហារ ព្រមទាំងគតិក្នុងផ្ទៃរឿងនេះផង បើមិនយល់ត្រង់ណា សូមសាកសួរនឹងវិញ្ញូជនផងចុះ បើមិនដូច្នោះទេ មិនខុសអ្វីពីមើលក្រដាសទទេ ឬមិនប្លែកពីពានរបានដូងទាំងសម្បកទេ ។

ម៉ី ម៉ូ

អ្នកពិនិត្យ

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ

# រឿងមហាភារតយុទ្ធ

## ភាគទី ១

## សេចក្តឫស្យានៃពួកញាត

ក្នុងយុគជាដំបូងនៃប្រជាវតាររបស់លោក ក្នុងប្រទេសឥណ្ឌៀភាគខាងលើ មានក្សត្រទ្រង់ព្រះនាមថា «សាន្តនុ» ជាពូជពង្សវង្សព្រះបាទ «ភរតៈ[1]» ដែលជាព្រះរាជឱរសរបស់ព្រះបាទ «ទុសយន្ត» និងនាង «សកុន្តលា» ជាបរមក្សត្រដែលល្បីល្បាញព្រះកិត្តិនាមជាងព្រះបាទសាន្តនុ ។ ក្សត្រអង្គនេះទ្រង់រក្សារាជប្រពៃណីនៃប្រយូរវង្សរបស់ព្រះអង្គទុកដោយប្រពៃ យកព្រះហឫទ័យទុកដាក់ពេចពិលរមិលមើលសុខទុក្ខរបស់ប្រជារាស្ត្រ ដោយការុណ្យចិត្តជាយ៉ាងក្រៃលែង ។ អ្នកនគរសមោសរស្រឡាញ់ព្រះអង្គ បាក់បីដូចជាដួងហឫទ័យរបស់គេ, គេរាប់អានតម្កុំតម្កើងលើកឡើងបូជាព្រះអង្គបីដូចជាទេវតាក្នុងសួគ៌ាល័យ ។ រាជសត្រូវស្ងប់ស្ងែងក្រែងខ្លាចព្រះតេជះបារមី គលដូចខ្លាចស្តេចខ្មោចក៏ប្រហែលគ្នា ។ ព្រះចរិយវត្តដែលប្រព្រឹត្តទៅជាប្រក្រតីយ៉ាងរាស្ត្រអ្នកជា មិនបានប្រកាន់ព្រះអង្គ, កាន់យកតែទ្រង់យុត្តិធម៌ គឺសេចក្តីជាអ្នកបរិសុទ្ធប្រាសចាក

១)- មើលថា,ភៈរៈតៈ ឬភៈរាត់ ។ ពាក្យឯទៀត ៗ មិនពន្យល់ទេសូមសាកថ្លានឹងលោកវិជ្ជាធរទៀតចុះ បើងឿងឆ្ងល់ពាក្យណា សូមទោស ។

មន្ទិល និងពាក្យដំណៀលនិន្ទា, ព្រះអាណាចក្រសោតក៏រីងឫទ្ធិរុងរឿងបីដូចសូរ្យរង្សី ។

សេចក្ដីស្ងប់ក្នុងប្រទេស និរាសភ័យអរិរាជសត្រូវ, និរាសសេចក្ដីវន្ទត់, នេះឯងជាអាការៈដ៏សំខាន់នៃការតាំងនៅបាននៃជាតិ និងពាណិជ្ជកម្មសព្វសារពើដែលជាលានធំ សម្រាប់ធ្វើឲ្យធនសម្បត្តិក្នុងប្រទេសដំណើរឡើងទៅកាន់វឌ្ឍនភាព, ព្រះអង្គជាអ្នកគ្រងរាជ្យនេះ ក៏បានយកព្រះហឫទ័យទុកដាក់ត្រួតត្រាមើលការខុសត្រូវរាល់វេលា, ទ្រព្យសម្បត្តិក៏សម្បូណ៌ហូរហៀរក្នុងព្រះនគរ, ទ្រង់ជ្រះថ្លាក្នុងសាសនកិច្ច ។ ព្រះអង្គសម្បូណ៌ដោយទស្សនវិជ្ជា និងព្រះរាជមតិ, ទ្រង់ប្រើសេចក្ដីត្រិះរិះកាញ់គ្នេរ ដោយព្រះវិចារណញ្ញាណដ៏ជ្រាលជ្រៅតាមគតិនិយមរបស់ជាតិនានា, របស់គណៈ, របស់ឯកជន, ទ្រង់ចាត់ចែងតាំងក្រុមសមាគមឲ្យមានរបៀបរៀបរយ និងទំនៀមទម្លាប់ជាប្រវេណីគតិទុកឲ្យរៀបរយ, កិច្ចការទាំងអម្បាលនេះ ធម្មតាប្រចាំនៅក្នុងព្រះរាជាណាចក្រធំទូលាយនេះទូទៅ ។ គ្មានអ្នកណាម្នាក់ស្គាល់ឡើយថាជាគ្រប់គ្រងបែបនេះ ៗ ខុសគន្លងធម៌, ទាំងទារុណកម្មក្ដី, អយុត្តិធម៌, អធម្មិករាជក្ដី ក៏ឥតអ្នកណាស្គាល់មុខមាត់វាថាជាយ៉ាងម្ដេចឡើយ ។ ប្រជាជនរាល់រូបមានចិត្តស្នេហាភក្ដី និងពេញចិត្តណាស់ ដែលបានម្ចាស់សមគួរជាប្រមុខរដ្ឋសោយរាជ្យដូច្នេះ ។

ព្រះបាទសាន្តនុ ស្ថិតនៅក្នុងរាជ្យសម្បត្តិទាល់តែដល់ទ្រង់ព្រះ



ជរាភាពហើយ ក៏ទិវង្គតទៅតាមយថាកម្ម វិចិត្តវិរ័យ ជាមកុដរាជកុមាររជ្ជទាយាទ បានឡើងសោយរាជ្យសម្បត្តិ តព្រះរាជសន្តតិវង្សមក ។ ក្សត្រីយ៍អង្គនេះ មានព្រះរាជឱរស ២ ព្រះអង្គ នាម ធ្ឫតរាស្ត្រ (ធតរដ្ឋ) ១, នាមបណ្ឌុ ១, កាលព្រះរាជានេះទ្រង់ទិវង្គតទៅហើយក៏កើតជាប្រស្នាចោទគ្នាឡើងថា យើងនឹងលើកក្សត្រីយ៍អង្គណាឲ្យឡើងសោយរាជ្យតទៅ ? នេះជារឿងជ្រាលជ្រៅល្អិតសុខុម កម្រអ្នកណានឹងទម្លុះទម្លាយប្រស្នានេះបានណាស់ ដ្បិតព្រះធ្ឫតរាស្ត្រ ជាព្រះរាជបុត្រច្បង បើតាមប្រពៃណីនិយម ត្រូវបានទទួលរាជ្យសម្បត្តិក៏ប៉ុន្តែទាស់នឹងព្រះនេត្រទាំងគូអន្ធការខ្វាក់តាំងពីកំណើត ហេតុដូច្នោះ រាជ្យសម្បត្តិត្រូវធ្លាក់ទៅលើបណ្ឌុ ជាព្រះអនុជវិញ បានជំនុំព្រមព្រៀងគ្នាអញ្ជើញព្រះបណ្ឌុ ឲ្យគ្រងពិភពតមក ។

កាលព្រះរាជាបណ្ឌុ សោយរាជ្យមកមិនបានយូរប៉ុន្មាន ក៏ទ្រង់ព្រះតម្រិះនឹងស្ដេចចេញចោលព្រះនគរ ទៅគង់នៅនាអរញ្ញប្រទេសតែមួយព្រះអង្គឯង ព្រោះទ្រង់សព្វព្រះហឫទ័យគ្រងព្រះជន្មទៅដោយសេចក្ដីវិវេគវិញជាការគាប់ប្រសើរជាង ក៏ប៉ុន្តែមិនដែលមានព្រះបន្ទូលប្រាប់អ្នកណាម្នាក់ឲ្យដឹងព្រះរាជមតិសោះ ព្រោះក្រែងរាជបរិពារទាំងឡាយមិនព្រមស្របតាម ឯក្នុងព្រះរាជកមលចេះតែនៅប៉ុនប៉ងយ៉ាងនោះដដែល ឥតរើរុះមិនចេះអស់មិនចេះហើយឡើយក្នុងទីបំផុត ក៏កើតនឿយណាយរឹតតែខ្លាំងឡើង ៗ ដោយបានទ្រង់

ព្រះសណ្ដាប់នូវតូរ្យតន្ត្រី ដែលចោមរោមរាជបល្ល័ង្កជុំវិញរាល់ទិវារាត្រី ទើបស្ដេចទ្រង់ដាក់រាជ្យសម្បត្តិ ហើយចេញចាកព្រះនគរពនេចរទៅគង់នៅនៃប្រទេស នាំយកទាំងព្រះអគ្គមហេសីសម្លាញ់ទៅជាមួយព្រះអង្គផង ។ លុះចំណិរចិរកាលមក ព្រះរាជាបណ្ឌុក៏ទិវង្គតនៅនាអរញ្ញប្រាសាទរាជអាស្រមនោះឯង ។ ព្រះរាជាអង្គនេះមានព្រះរាជឱរស ៥ ព្រះអង្គ គឺ៖

ទី១-ព្រះនាម «យុធិស្ធិរ» ល្បីនាមថាជាក្សត្រិយ៍ចូនធូរក្នុងសច្ចធម៌ និងសទ្ធាជ្រះថ្លា ។

ទី២-ព្រះនាម «ភីម» ល្បីនាមថាជាក្សត្រិយ៍ទ្រង់នូវព្រះកាយពលដ៏មហិមា ខុសនឹងកម្លាំងមនុស្សធម្មតា មនុស្សទាំងពួងញញើតព្រះកាយពលនៃព្រះអង្គណាស់ ។

ទី៣-ព្រះនាម «អរជុន» ល្បីនាមជាក្សត្រិយ៍មានថ្វីព្រះហស្តក្នុងយុទ្ធវិធី និងការប្រើអាវុធផ្លូវយុទ្ធសាស្ត្រ ។

ទី៤ និង ទី៥-ព្រះនាម «នកុល» និង «សហទេព» មួយគូនេះជាព្រះរាជបុត្រភ្លោះ ជាព្រះអនុជបន្ទាប់នឹងព្រះអរជុន ។

កាលដំណឹងទិវង្គតនៃព្រះបាទបណ្ដុលេចឮជ្រួតជ្រាបទៅដល់ព្រះនគរហើយ អ្នកនគរទាំងអស់បាននាំគ្នាពាក់គ្រឿងកាន់ទុក្ខ ថ្វាយតាមព្រះរាជប្រពៃណី និងយំសោកសម្ដែងអាការៈស្ដាយស្រណោះអាឡោះអាល័យព្រះរាជារបស់ខ្លួន ហាក់ដូចជាញាតិដ៏ជិតស្និទ្ធរបស់



គេម្នាក់ស្លាប់ដូច្នោះ ។ ចំណែកព្រះញាតិវង្ស ព្រមដោយរាជបរិពារបាននាំគ្នាទៅអញ្ជើញព្រះនាងអគ្គមហេសី ជាស្ត្រីវិធវា និងបាណ្ឌពកុមារទាំង ៥ អង្គ ឲ្យត្រឡប់ចូលមកកាន់ក្រុងហស្តិនបុរវិញ ឲ្យសំណាក់នៅក្នុងវាំងនៃព្រះបាទធ្ឫតរាស្ត្រ (ក្សត្រិយ៍ខ្វាក់) ។ ឯព្រះរាជឱរសទាំង ៥ អង្គរបស់ព្រះនាង ព្រះបាទធ្ឫតរាស្ត្រ ជាព្រះរាជបិតុលាក៏ទ្រង់ឧបត្ថម្ភឲ្យរៀនសូត្រសិល្បសាស្ត្រផ្សេង ៗ ជាមួយនឹងព្រះរាជឱរសរបស់ព្រះអង្គ មានទុរយោធន៍ជាដើម ។

កាលព្រះរាជកុមារព្រះជេដ្ឋា និងព្រះអនុជទាំង ៥ អង្គ ចម្រើនវ័យវឌ្ឍនាការឡើង សឹងមានរូបរាងស័ក្តិសម, ព្រះឱរជំទូលាយអវយវៈមានលក្ខណៈគ្រប់យ៉ាង ទាំងដំណើរយាងយាសយាត្រា និងកិរិយាមារយាទ ក៏ល្អល្អះ មានរាសី សង្ហាស្វាហាប់ ជាហេតុធ្វើឱ្យពួកអ្នកនគរនឹកសង្ឃឹមក្នុងព្រះរាជកុមារទាំង ៥ ទ្វេចំនួនច្រើន ១ ឡើងដោយលំដាប់ ។ ព្រះគុណសម្បទដែលជាទីនិយមនៃប្រជុំអនេកនិករជនក្នុងរជ្ជកាលនៃព្រះរាជបិតា បានធ្លាក់មកជាមត៌ករបស់ព្រះរាជកុមារទាំង ៥ អង្គពេញបន្ទុកដូចយ៉ាងព្រះរាជបិតាដែរ ប៉ុន្តែព្រះគុណសម្បទទាំងនេះ ប្រែក្លាយទៅជារបស់ស្លែងមានពិសពុលវិញ ព្រោះធ្វើឲ្យទុរយោធន៍ ព្រមទាំងព្រះរៀម ព្រះអនុជ និងបក្សពួករបស់ទុរយោធន៍ នាំគ្នាឫស្យាច្រណែនក្នុងបាណ្ឌពកុមារ ដែលជាព្រះជេដ្ឋា ព្រះអនុជរួមព្រះអយ្យកោមួយជាយ៉ាងក្រៃលែង ។

ព្រះកុមារទាំង ៥ បានសិក្សាការប្រើសស្ត្រាវុធផ្សេង ៗ រាល់ថ្ងៃក្នុងរាជសេដ្ឋវិទ្យា គឺការប្រើធ្នូស, ការប្រើរថសឹក, ការកាប់ដាវនិងដាវ, ពួយលំពែង, គុន, ដាល់, ចំបាប់, និងហាត់វិជ្ជាយ៉ាងដទៃទៀតជាច្រើនមុខ ដែលជាភាគនៃរាជវតី ឬជាការហាត់សមសម្រាប់ក្សត្រិយ៍ជាតិអ្នកចម្បាំងក្នុងសម័យនោះយ៉ាងស្ទាត់ ។ គ្រូអាចារ្យ អ្នកបង្វឹកបង្ហាត់រាជកុមារអម្បាលនេះ ជាព្រាហ្មណ៍មានត្រកូលនាមថា «ទោណអាចារ្យ» ជាប្រាជ្ញមានគុណគួររាប់អាន មានមុខងារជាអ្នកប្រិតប្រៀនវិជ្ជាទាហានដល់ក្សត្រិយ៍គ្រប់អង្គក្នុងរាជត្រកូលនោះ ។

ទោណាចារ្យបានទូលស្នើព្រះភីស្មៈ (ជាព្រះរាជឱរសនៃព្រះបាទសាន្តនុ និងព្រះនាងគង្គារ ត្រូវជាព្រះបិតុលានៃព្រះបាទធ្មត-រាស្ត្រ) កំណត់ទុកថា កាលរាជកុមារអម្បាលនេះ រៀនយុទ្ធវិទ្យាចេះស្ទាត់ហើយ នឹងបានជាកម្លាំងជួយធ្វើសង្គ្រាមតនឹងព្រះបាទទ្រុបទជាម្ចាស់ដែនដីបញ្ចាលនគរ ដែលជាអរិរាជសត្រូវនឹងព្រះអង្គមកអំពីថ្ងៃមុន ។

ទោណាចារ្យយកចិត្តទុកដាក់ប្រៀនប្រដៅ និងស្រឡាញ់ប្រណីបាណ្ឌពកុមារទាំង ៥ អង្គជាសិស្សយ៉ាងខ្លាំង ។ ការរៀនវិជ្ជាគ្រានោះ អរជុនស្ទុះល្បឿនទៅមុខព្រះជេដ្ឋា ព្រះអនុជរួមឯកមាតុទរ និងរួមអយ្យកោមួយទាំងអស់អង្គក្នុងផ្លូវវិទ្យាអ្នកចម្បាំង, មានសតិបញ្ញាស្រស់ស្រួចជាងគេ, ហើយជាអ្នកធ្ងន់ធ្ងរក្នុងហិរោត្តប្បៈ, ជាអ្នក



ដែលគេប្រដៅងាយជាងព្រះជេដ្ឋា ព្រះអនុជទាំងពួង ។ ឯការុណ្យចិត្ត ដែលទោណាចារ្យសម្ដែងចេញមកខាងក្រៅដូច្នេះ ជាហេតុបណ្ដាលឲ្យទុរយោធន៍ខ្វេសេចក្ដីឫស្យាក្នុងព្រះកុមារទាំង ៥ អង្គថែមឡើងទៀតជាច្រើន ហើយនិងឫស្យាច្រណែនស្អប់អរជុន ដែលមានថ្វីព្រះហស្តពូកែជាងគេ ជាយ៉ាងខ្លាំងបំផុត ។

លុះព្រះរាជកុមារអម្បាលនេះ រៀនវិជ្ជាទាហានចេះចប់សព្វគ្រប់ហើយ គេបានចាត់ការប្រឡងល្បងមើលថ្វីព្រះហស្តនៃកុមារអ្នកចម្បាំងទាំងអម្បាលនោះ ។ ពេលនោះមានបណ្ដាជនជាច្រើនបបួលគ្នាមកកាន់ទីប្រជុំ ដើម្បីមើលការប្រឡងប្រជែង បានស្រែកហ៊ោទះដៃសម្ដែងសេចក្ដីត្រេកត្រអាលឮសូរស័ព្ទទ្រហឹងអឹងកង ។ ចំណែកពួកអ្នកប្រឡង ក៏ចូលល្បងឫទ្ធិគ្នាតាំងចិត្តចេតនាប្រឹងប្រែងសម្ដែងថ្វីដៃយ៉ាងពេញកម្លាំង ប៉ុន្តែមិនយូរប៉ុន្មាន ការប្រកួតប្រណាំងនោះ មិនមែនត្រឹមតែសាកចំណេះវិជ្ជាគ្នា ឬក៏សម្ដែងឫទ្ធិឲ្យល្អមើលប៉ុណ្ណោះទេ គូប្រឡងទាំងសងខាងបែរជាបណ្ដាលទោសខ្លាំងឡើងតស៊ូគ្នាទៅជាការមែនទែនតែម្ដង ។ ទុរយោធន៍ចាប់គូស៊ូគ្នានឹងភីម គូបដិបក្ខទាំងពីរនេះ បានចូលប្រឡូកប្រឡេះឫទ្ធិគ្នាយ៉ាងពេញថ្វីព្រះហស្តទាំងសងខាង ក៏រឹងរឹតតែបណ្ដាលទោសោខ្លាំងឡើង ៗ ស្ទើរតែនឹងបាតុឈាមគ្នាទៅវិញទៅមក ។ គ្រានោះមានមនុស្សម្នាក់ចូលទៅហាមប្រាម ដោយទទូលព្រះរាជបញ្ហាអំពីព្រះរាជា និងអំពីទោណា-

ចារ្យជាគ្រូធំ ទើបបានគ្រាក់ចេញពីគ្នាផុតទៅ ក៏លើកការប្រឡងនៅពេលថ្ងៃត្រង់ ។ លុះដល់វេលារសៀលថ្ងៃដដែលនោះ មានអ្នកចម្បាំងប្លែកមុខចូលមកក្នុងស្នាមយុទ្ធម្នាក់ទៀត ឈ្មោះថា «កណ៌» ប៉ុន្តែគេជាត្រកូលអ្វីឥតអ្នកណាដឹងស្គាល់ បានចូលចាប់គូតស៊ូនឹងអរជុនដែលជាអ្នកក្លៀវក្លាសំខាន់ បញ្ចេញស្នាដៃឲ្យអ្នកគយគន់ទាំងឡាយឃើញថា ខ្លួនគេជាគូគួរនឹងអរជុន ។ ទុរយោធន៍ឃើញកម្លាំងស្នាដៃកណ៌ហើយ ក៏សព្វព្រះរាជហឫទ័យណាស់ ឲ្យនាំខ្លួនចូលទៅគាល់ឯវាំង ប្រទានរង្វាន់ជាច្រើន ហើយទ្រង់ជប់លៀងទុក ជាសេនាទាហានរបស់ព្រះអង្គ ។

ការប្រឡងថ្វីដៃគ្រានេះ ជាហេតុរុករុញទុរយោធន៍ឲ្យកើតសេចក្តីឫស្យាច្រណែននិន្ទាបាណ្ឌពកុមារកាន់តែខ្លាំងឡើង ដោយហេតុដែលទ្រង់ទទាក់ទទួលយកមនុស្សមានជាតិ ដ៏ថោកទាបដូចយ៉ាងកណ៌ទុកនេះ គឺស្មើដូចជាគេយកឧសមកបង់ចុះក្នុងគំនរភ្លើង ឬថែមចំណីឲ្យភ្លើងក៏ប្រហែលគ្នា រមែងពោលអួតខ្លួនហើយ ញុះញង់បងប្អូន ឬមិត្រសម្លាញ់របស់គេឱ្យបែកគ្នា ។

កុមារទាំង ៥ ជាព្រះរៀមព្រះអនុជកំព្រាព្រះបិតា មានសេចក្តីចង្អៀតចង្អល់ ក្តៅក្រហាយព្រះទ័យជារាល់ថ្ងៃ តែក៏ខំទ្រាំអត់សង្កត់សេចក្តីប្រមាថមើលងាយគ្រប់ប្រការ ទាំងក្នុងព្រះរាជស្ថាន ទាំងក្នុងទីប្រជុំជន មានទីកណ្តាលថ្នល់ជាដើម មិនតតបវិញសោះ មើលទៅ



មិនខុសអ្វីពីឆ្កែ ឬឆ្មា ដែលជាសត្វតិរច្ឆាននោះឡើយ ។ ធ្រឹតរាស្ត្រទ្រង់ជ្រាបនូវការប្រមាថព្យាបាទមើលងាយរបស់ទុរយោធន៍ ដោយប្រើជាញាណ ដែលជាអ្នកឈ្លាសវៃក្នុងរដ្ឋប្រសាសនោបាយ ហើយទ្រង់ក៏ឲ្យប្រឡែងស្ថានព្រះភាគិនេយ្យទាំង ៥ អង្គ ឲ្យស្តេចចេញទៅគង់នៅឯវារណាវ័ត, ទោះបីម្លឹងហើយ ទុរយោធន៍ដែលជាមនុស្សប្រកបដោយប្រទុស្តចិត្តប្រក្រតី ក៏នៅតែមិនព្រមបណ្តោយឲ្យព្រះកុមារទាំង ៥ អង្គ បាននៅជាសុខសាន្តឡើយ ចេះតែតាមទៅបៀតបៀនផ្តន្ទាទៀត គឺទ្រង់ឲ្យសាងវាំងមួយដ៏ធំ ប្រកបដោយក្រមួន, ជ័រស្រស់, ជ័រទឹក និងវត្ថុដទៃទៀតដែលជាចំណីភ្លើង ហើយឲ្យជាងយកកំបោរបូកលាបពីក្រៅយ៉ាងជិតស្និទ្ធរលង់រលើប ធ្វើឲ្យអ្នកផងទស្សនាឃើញរូបឥដ្ឋ និងសិលា ដើម្បីអញ្ជើញព្រះកុមារទាំង ៥ អង្គឲ្យទៅគង់នៅ ។ ការសាងវាំងឡើងយ៉ាងនេះ ដោយចេតនាបំណងនឹងបំផ្លាញបាណ្ឌពកុមារដោយអគ្គី ប៉ុន្តែនៅមានអ្នកអាណិតអាសូរខ្លះដែរ គឺវិទូរ(ជាឱរសនៃព្រះរាជាកុរុ)ជាអ្នកមានសតិបញ្ញាវាងវៃបានខ្សឹបប្រាប់ការណ៍ជាអាថិកំបាំងនេះ ឲ្យព្រះរាជកុមារទាំង ៥ ដឹងព្រះអង្គជាមុន ។ លុះសាងមន្ទីរស្រេចហើយ ទុរយោធន៍ក៏អញ្ជើញកុមារទាំង៥ ភាតាឲ្យទៅអាស្រ័យនៅក្នុងវាំងថ្មីនោះ ដោយអាងហេតុថាក្នុងព្រះមហារាជវាំងគ្មានដំណាក់ នឹងចែកឲ្យគង់នៅគ្រប់គ្រាន់គ្នា ។

ជួនជាវេលាគ្រោះកាចអាក្រក់មកដល់ ក្នុងរាត្រីកាលមួយនោះ

ជាយប់ងងឹតឈឹងសូន្យ ពពកខ្មៅមីរដេរដាសបិទបាំងអាកាស គន់មើលមិនយល់អ្វី ។ អ្នកស្រុកកំពុងតែដេកលក់ស៊ប់គ្រប់ផ្ទះសម្បែង ស្ងាត់ច្រៀបឥតមនុស្សម្នាក់ដើរទៅមក តាមមាត់ផ្លូវហ្លួងសោះឡើយ ស្រាប់តែនៅខណៈនោះ វាំងធំធេងដែលទើបនឹងសាងឡើងថ្មី ៗ ក៏ស្រាប់តែលេចអណ្ដាតភ្លើងភ្លឺសន្ធោសន្ធៅច្រាលរន្ទាលឡើង ឮសូរសន្ធឹកផ្ទូងផាង ៗ មួយស្របក់វាំងថ្មីនោះ ក៏ទ្រុឌទ្រោមក្លាយទៅជាផេះអស់ ។ ចំណែកបាណ្ឌពកុមារ ក៏មិនឥតគំនិត ឬធ្វេសប្រហែសក្នុងរឿងដ៏ស្ដែងនេះដែរ បានទ្រង់ជ្រាបរហ័សកម្ម មកយូរថ្ងៃជាមុនស្រេចហើយ ទើបបាននាំគ្នា បលាយនាការគេចវេះ ចេញឲ្យផុតអំពីអគ្គីភ័យ ទៅតាមផ្លូវដែលជីករូងជាប្រហោងក្នុងដីទុកតាំងពីថ្ងៃមុន ផុតព្រះនេត្រព្រះកាណ៌ទុរយោធន៍ និងអ្នកឯទៀត ៗ ឥតអ្នកណាដឹងយល់ដល់ម្នាក់ឡើយ ។

គ្រានោះ ទុរយោធន៍រីករាយសប្បាយចិត្តណាស់ ដែលខ្លួនបានទំលាយបំផ្លាញគូសត្រូវ ឲ្យបានសម្រេចដូចសេចក្ដីប្រាថ្នា ទំនងដូចគ្នានឹងព្រះពាលរាជា ១ អង្គទៀតក្នុងបោរាណសម័យ, ព្រះអង្គទ្រង់ខ្ពុយឮឆ្វេត ៗ ក្រសាលក្សេមក្សាន្ត ជាការត្រេកត្រអាល កមលហាឫទ័យ នៅខណៈដែលព្រះអគ្គីកំពុងតែឆាបឆេះលំអិតវាំង ឮសូរផ្ទូងផាង គ្រាំគ្រេងនោះឯង ។

កម្មមុខគួរឲ្យស្ញែង ដែលទុរយោធន៍បានធ្វើទៅដោយប្រទូស្ត



ចិត្តគ្រានេះ ជាគ្រឿងចង្អុលបង្ហាញឲ្យបណ្ដារាស្ត្រទូទៅ ដឹងឮយ៉ាងច្បាស់លាស់ ថាខ្លួនគិតគុំកួនផុតបាណ្ឌពកុមារច្បង គឺយុធិស្ឋិរ ដើម្បីយករាជ្យសម្បត្តិឲ្យបានជាសិទ្ធិដាច់ខាតមកលើខ្លួនទាំងមូល ។ ទុរយោធន៍បានខំគិតបិទបាំងរហ័សកម្មនេះទុកយ៉ាងសំខាន់ ប៉ុន្តែបុរាណលោកបានភាសិតទុកមកហើយថា ការណ៍សម្ងាត់ដែលគេប្រឹងបិទបាំងណាស់ ក៏នៅតែលេចឮរន្ទឺចេញបាន សូម្បីកប់កំបាំងបាត់ស្ងាត់នៅក្នុងដួងហឫទ័យរបស់ព្រះបរមក្សត្រិយ៍ ក៏គង់តែមានគេដឹងឮដែរ ព្រោះថាធម្មតាអណ្ដាតមិនដែលនៅស្ងៀមឈឹងទេ តែងតែរលាស់បញ្ចេញសូរស័ព្ទឲ្យដំណឹងទៅខាងក្រៅជាអាចិណ្ណ ។ មុនដំបូងក៏គ្រាន់តែខ្សឹបខ្សៀវគ្នាប៉ុណ្ណោះ លុះកន្លងមកមិនយូរប៉ុន្មាន ក៏លាន់ឮខ្លាំង ។ ដូចគេសន្ទនាគ្នាជាធម្មតា គ្រប់ផ្ទះសម្បែង គ្រប់ទីកន្លែងផ្លាថ្នល់ និងផ្សារ ឥតអ្នកណាកោតក្រែងស្ដេច ឬចៅហ្វាយនាយខ្លួនឡើយ ។ ហេតុការណ៍ដែលកើតមានឡើងទាំងនេះជារឿងមុខគួរឱ្យខ្ពើមរអើមពេកណាស់ ។ ហេតុនោះ កាលកន្លងមកមិនយូរប៉ុន្មានរហ័សកម្មនោះ ក៏លេចឮសាយភាយទូទៅ សម្លេងនិន្ទា និងផរុសវាទ ក៏ធ្លាក់មកត្រូវលើទុរយោធន៍ កលដូចជាគ្រាប់ភ្លៀងដែលស្រក់ចុះចាកនភាកាស ។

ចំណែកកុមារទាំង ៥ ភាតា ព្រមដោយព្រះជននីក៏នាំគ្នាលីលាយាត្រាចេញចាកព្រះនគរ បែរភក្ត្រឆ្ពោះសំដៅអារណ្យប្រទេស យក

ព្រៃព្រឹក្សាជាតិជាទីពឹង ក្នុងរវាងកាលដែលពនេចរទៅ បានត្រូវកំដៅថ្ងៃ, ត្រូវខ្យល់ភ្លៀង, និងសេចក្ដីនឿយព្រួយលំបាក ស្រេកឃ្លានសព្វទិវារាត្រីកាល មានតែសេចក្ដីអំណត់អត់ធ្មត់ គឺអធិវាសនខន្តីនេះឯងជាគ្រឿងការពារក្ដៅរងា និងសម្រេកគម្លានប៉ុណ្ណោះ ។ ជួនកាល ព្រះមាតា និងបុត្រអស់ព្រះកាយពលណាស់ ក៏នាំគ្នាឈប់សម្រាកព្រះកាយាខាងមាគ៌ា កាលល្ហែស្រាលទុក្ខព្រួយហើយ ក៏នាំគ្នាត្រាច់ពនេចរ យាត្រាតទៅមុខទៀត ជួនកាលត្រូវឆ្លងគង្គាក៏នាំគ្នាព្យាយាមហែលទឹកឆ្លងទៅឯត្រើយនាយ ក្រសែទឹកជាត់ជាយផ្កាប់ផ្ងារ ទម្រាំតែទៅដល់ត្រើយជលសា ដែលឆ្ងាយលន្លឹមលន្លោចនោះ ក៏អស់ព្រះកាយពលទៀបដាច់ខ្យល់អស្សាសបស្សាស បានរួចអំពីគ្រោះថ្នាក់ទៅម្ដង ៗ ហាក់បីដូចបានកើតឡើងជាថ្មីម្ដងទៀត ។ កាលបើបានរួចពីនោះទៅហើយ នឹងរកទីសំណាក់ភ័កអាស្រ័យក៏ពុំបាន តោងនាំគ្នាដើរកាត់ភូមិប្រទេស ដ៏ដាច់សង្វែងនោះសន្សឹម ៗ ទៅទៀត ទាល់តែព្រះមាតាស្ងួតខះព្រះសុរង ស្រេកទឹកខ្លាំងណាស់ ក៏ប្រេះប្រាណលើប្រឹថពី ។ ភីមអាណិតព្រះមាតាពេក ក៏ខំត្រាច់ស្វះស្វែងរកវារី តែគ្មានអ្វីនឹងដួសដងយកមក ទើបដោះសំពត់ឈ្នួតមកជ្រលក់ទឹកឲ្យជោកហើយ ក៏ម៉្នីម្នារត់យកមកពួតបន្តក់សម្រក់ចូលក្នុងព្រះឱស្ឋព្រះមាតា ជួយឃីតយោងព្រះជន្មព្រះមាតា ឲ្យរួចរស់ទៅបានមួយគ្រា ប៉ុន្តែទឹកក្នុងសំពត់ឈ្នួតនោះតិចណាស់ មិនល្មមនឹងរំលេមបំពង់ក ព្រះភាតា



៤ អង្គទៀតដែលជាអ្នកនឿយហត់លំបាកមកតាមផ្លូវកន្ដារជាមួយគ្នាទាំងឃ្លានភោជនាហារក៏សែនឃ្លាន គ្មានប្រទះផលាផលឯណានីមួយដែលគួរនឹងសោយសោះ ។ ក្នុងថ្ងៃនេះព្រះមាតា និងបុត្រ មិនអាចធ្វើដំណើរតាមផ្លូវទៅបាន ក៏ឈប់ខានសម្រាកព្រះកាយនៅក្រោមរុក្ខា តែកាយ និងចិត្តភីមមិនបានសម្រាកសម្រាន្តផងឡើយ ដោយអំណាចឈឺចាប់ក្ដួលក្ដៅម្ញូមៅក្នុងកមលសន្ដានណាស់ អង្គុយនិយាយតែ ១ អង្គឯងរអ៊ូថា អ្នកណាមួយអាចនឹងចៀសវាងឲ្យផុតពីលិខិតនៃព្រះជាម្ចាស់លើស្ថានសួគ៌បាន ឱកម្មអើយកម្ម ! កម្មដែលបងប្អូនយើងមកទ្រាំរងវេទនា ត្រាំត្រែងគ្រានេះ ចិត្តយើងក្ដៅអីក៏ក្ដៅម្ល៉េះ ទៅមុខប្រហែលគ្រោះកាចនឹងមានដល់យើង ច្រើនលើសទុក្ខពេលនេះទៅទៀតឬអ្វី? យុធិស្ឋិរជាក្សត្រិយ៍គួរតែមានរាជសម្បត្តិក្នុងប្រទេសកុរុរដ្ឋណាស់ ប៉ុន្តែឥឡូវនេះបែរជាមកផ្ទំនៅកណ្ដាលខ្សាច់វិញ នឹងរកកម្រាលក្រាលផ្ទំប៉ុនបាតដៃក៏គ្មាន, ចំណែកទុរយោធន៍អ្នកដណ្ដើមរាជ្យសម្បត្តិនោះ គេដេកអង្គុយលើកម្រាលក្រាលលាតសន្ធឹងយ៉ាងស្អាតបាត ពេញពោរទៅដោយគ្រឿងលើកតម្កើងស័ក្តិយស និងតេជានុភាព, ព្រះរៀមរបស់យើងជាមនុស្សព្រះទ័យទន់មិនស្ទូវចេះប្រកាន់ទោសក្រោធខ្ញាល់នឹងអ្នកឯណា ចេះតែឲ្យអភ័យដល់គេងាយ ៗ កុំអីក៏... ... ម្ល៉េះសមគេសោយសុខសម្បត្តិត្រេកត្រអាលចិត្តគេរីករាយស្មើរនឹងអណ្ដែតឡើងទៅជាប់ឯស្ថានសួគ៌ ។

## ភាគទី ២

# ការស្វយម្ពរ[១]នៃព្រះនាងទ្រៅបទី

សូមឲ្យអស់លោក-អ្នកនាង នឹកឃើញចុះថា ព្រះមាតា និងបុត្រ ដែលត្រូវគេនិរទេសចាកនិវេសន៍រាជស្ថានចេញទៅទាំងរត្តិកាលនោះ តើមានសេចក្ដីទុក្ខព្រួយនាយបាត់ល្វិតល្វៃយ៉ាងណាខ្លះ ? ប៉ុន្តែបើទុកជាដល់ថ្នាក់ម្លឹង ៗ ហើយក៏ដោយ ក៏ជាតិជាខត្តិយអ្នកចម្បាំងនៅតែមានអស្មិមានះជាធម្មតា បណ្ដើរគ្នាយាត្រាកាត់ព្រៃទៅលេចវាលចូលព្រៃ ដោយស្មាន ៗ ក្នុងព្រះហឫទ័យមិនដឹងជាគ្រោះកម្ម វានឹងដឹកនាំទៅដល់ទីកន្លែងណាទេ ? មួយវិញទៀតនឹកបារម្ភក្រែងពួកសត្រូវដិតដានតាមមកយាយី ទើបនាំគ្នាដោះគ្រឿងទ្រង់ចេញពីព្រះអង្គចេញអស់ យកលំអិតផង់ធូលីខ្មៅមកប្រឡាក់លាបព្រះកាយផ្លាស់ប្ដូរតែងភេទជាព្រះយោគី ដើម្បីសូមឲ្យគ្រាន់តែរួចខ្លួនទៅបន្តិចប៉ុណ្ណោះ ។ ឯព្រះជននីសោត ក៏តោងតែប្លមព្រះអង្គ ឲ្យដូចជាស្ត្រីអនាថាដែរ ។

ខណៈដែលក្សត្រិយ៍ទាំងនោះ ធ្វើដំណើរតាមផ្លូវទៅ គាប់ជួនជាថ្ងៃមួយ ព្រះមាតា និងបុត្របានជួបប្រទះនឹងព្រាហ្មណ៍ ១ ពួកគេប្រាប់ថា គេនឹងទៅក្នុងការស្វយម្ពរធីតាព្រះបាទបញ្ចាលរាជ, ការ

១)- ការរើសរកគូព្រេង ។



ស្វយម្ពរគ្រានេះ ជាការធំដុំអ៊ឹកធឹកណាស់ ភ្ញៀកមនុស្សម្នានឹងបានជួបប្រទះឃើញតែត្រឹមមួយដងមួយកាលប៉ុណ្ណោះ ។ បាណ្ឌពកុមារ បានឮដូច្នោះក៏រៀបចំខ្លួននឹងធ្វើដំណើរទៅកាន់ដែនបញ្ចាលដែរដើម្បីនឹងចៀសចាកភ័យអន្តរាយជាងសេចក្ដីបំណងទៅមើលការស្វយម្ពរ ។

លុះដល់បញ្ចាលរាជធានី ដែលជាប្រទេសធ្លាប់កើតបដិបក្ខនឹងគ្នាមកអំពីដើម ដ្បិតទ្រង់ទើបតែធ្វើសង្គ្រាមនឹងគ្នាមកថ្មី ៗ មិនទាន់ជាយូរប៉ុន្មាន ដោយបញ្ជាការនៃទោណាចារ្យ តែទោណាចារ្យឲ្យលើកទោសព្រះបាទបញ្ចាលរាជដ៏ជាបច្ចាមិត្រ ទុកជីវិតឲ្យម្ដង, ទាំងបានប្រគល់ដែនដីដែលមានជ័យជម្នះ ឲ្យត្រឡប់ទៅវិញ តាំងពីគ្រានោះមក ព្រះបាទទ្រុបទ ម្ចាស់ផែនដីបញ្ចាលរដ្ឋ ឃើញសេចក្ដីក្លាហានក្នុងពិជ័យសង្គ្រាមនៃបាណ្ឌពកុមារទាំង ៥ ព្រះអង្គ គឺទ្រង់សព្វព្រះរាជហឫទ័យមានចំណង់នឹងលើកព្រះរាជធីតា ឲ្យជាបាទបរិចារិកានៃបាណ្ឌពកុមារ គឺនឹងទ្រង់លើកឲ្យអរជុន ប៉ុន្តែរឿងនេះទ្រង់នឹកតែក្នុងព្រះហឫទ័យមិនបានចេញព្រះវាចា ឬប្រាប់ព្រះរាជតម្រិះដល់អ្នកឯណាឡើយ ព្រោះសិទ្ធិនៃការរើសគូ មិនមែននៅក្នុងអំណាចនៃព្រះអង្គជាបិតាទេ គឺស្រេចនៅលើទ្រៅបទី ដ៏ជាព្រះរាជធីតានឹងស្មោះស្ម័គ្រ ឬមិនស្មោះស្ម័គ្រប៉ុណ្ណោះ ប៉ុន្តែដើម្បីទ្រង់នឹងប្រតិបត្តិការឲ្យសមព្រះរាជហឫទ័យក្នុងរឿងនេះ ទើបទ្រង់ឲ្យចាត់ការម្យ៉ាង ដែលទ្រង់ជឿជាក់ក្នុងព្រះហឫទ័យថា អ្នកនឹងអាចធ្វើការ

នោះបានសម្រេច មានតែអរជុន មួយនាក់ប៉ុណ្ណោះ គឺទ្រង់ឲ្យធ្វើមហាធ្នូ ១ ឲ្យយកទៅចងព្យួរនៅចុងសសរដ៏ខ្ពស់ មានកងចក្រវិលខ្វាល់នៅពីខាងក្រោម ។ ក្នុងរឿងនេះ មានសេចក្ដីសន្យាថា «អ្នកដែលជាគូព្រេងរបស់ព្រះរាជធីតា តោងតែជាអ្នកអាចឃឹតមហាធ្នូនោះបាន ដោយកម្លាំងខ្លួនម្នាក់ឯង ដាក់ព្រួញផ្គងបាញ់ចេញទៅ ឲ្យព្រួញរត់ទៅតាមចន្លោះស្លាបចក្រ កុំឲ្យប៉ះពាល់ទង្គិចស្លាបចក្រ រហូតទៅត្រូវភ្នែកត្រីមាសដែលព្យួរពីខាងលើ ឲ្យត្រីមាសនោះធ្លាក់ចុះមកដល់ដី, អនុញ្ញាតឲ្យអ្នកដែលចូលប្រឡង ដណ្ដើមយកនាងរាល់ ១ គ្នា បាញ់បានតែត្រឹម ៥ ព្រួញក្នុងម្នាក់ ១ ប៉ុណ្ណោះ» ។ ព្រោះហេតុនេះ បណ្ដាអ្នកបាញ់ទាំងប៉ុន្មាននាក់ ទ្រង់ជឿជាក់ថាមានតែអរជុន ម្នាក់ប៉ុណ្ណោះទេ ដែលអាចបាញ់ត្រូវត្រង់វង់ជាទីសំគាល់បាន ។

សម្រាប់ការស្វយម្ពរនេះ ព្រះបាទបញ្ចាលរាជ មានព្រះរាជបញ្ជាឲ្យចូកចាំងជម្រះទីកន្លែងដីធំ ហើយឲ្យសង់ព្រះពន្លាពាសសំពត់សមានកំពូលដូចមណ្ឌប បិទមាសប្រដាប់ដោយកែវមណីផ្សេង ៗ ភ្លឺប្រាលរន្ទាល មានការជប់លៀងភោជនាហារ និងលេងល្បែងនានាក្នុងព្រះរាជវាំង នៅវេលាមុនប្រឡងធ្នូសិល្ប៍ប្រមាណជាពីរសប្ដាហៈ ។ លុះដល់ថ្ងៃប្រឡង ក្សត្រិយ៍ទាំងឡាយដែលចង់បានព្រះរាជធីតាជាបំណាច់ថ្វីដៃ ក៏នាំគ្នាមកសន្និបាត គង់ចាំត្រៀបត្រាតាមទីកន្លែងរៀងខ្លួន ក្នុងរោងទងមុខព្រះពន្លាហ្លួងគង់ដំកង់ជាវង់



ដូចរូបព្រះចន្ទ្រពាក់កណ្ដាលដួង បែរព្រះភក្ត្រទៅរកព្រះពន្លាគ្រប់ព្រះអង្គ ។

លុះក្សត្រិយ៍ទាំងឡាយគង់រៀបរយស្រួលបួលហើយ នាងទ្រៅបទី ក៏ស្ដេចយាត្រាចូលមកដ្ឋានទីប្រជុំ ព្រះហស្តដ៏ទន់ភ្លន់ដូចប្រមោយព្វាវ័ណកាន់ភួងមាល័យមួយមកផង ដួងមាល័យនេះប្រៀបដូចព្រះវរលញ្ឆករ (ត្រា) ដែលនាងត្រូវតាក់តែងព្រះអង្គក្នុងការរើសគូស្នេហ៍គ្រងរបស់នាងឲ្យបានជាការដាច់ស្រេច ។

បណ្ដាក្សត្រិយ៍ ដែលចូលមកប្រជុំក្នុងការស្វយម្ពរគ្រានេះមាន ទុរយោធន៍, កណ៌, បាណ្ឌពកុមារបងប្អូន ៥ អង្គ, ក្រឹស្ណៈ, ពលរាម ជាអនុជក្រឹស្ណៈ, ក្សត្រិយ៍យាទពច្រើនអង្គ, ព្រះរាជាសិន្ធូ ព្រមទាំងព្រះឱរស (មិនប្រាកដថាប៉ុន្មានអង្គ) ព្រះរាជាចេតិយ, ព្រះរាជាកោសល, ព្រះរាជាមទ្រៈ និងនៅមានក្សត្រិយ៍ក្រៅអំពីដែលចេញព្រះនាមមកហើយជាច្រើនអង្គ ។ ប៉ុន្តែបាណ្ឌពកុមារទាំង ៥ អង្គ មិនបានចូលទៅគង់ក្នុងចំណោមក្សត្រិយ៍ទាំងអម្បាលនោះទេ បែរជាទៅគង់ក្នុងចំណោមពួកព្រាហ្មណ៍មួយពួកផ្សេងទៅវិញ ព្រោះទ្រង់ប្លែងភេទប្លមអង្គជាព្រាហ្មណ៍មកក្នុងវេលានោះ ។ ភ្នែកមនុស្សទាំងអស់សម្លឹងមើលតែឆោមលំអនៃព្រះនាងទ្រៅបទី ។ ឯទីសន្និបាតនោះ សូម្បីមានមនុស្សច្រើនជ្រៀតបៀតញៀតញាត់គ្នាទាំងម្លឹង ក៏ស្រាប់តែស្ងប់ស្ងាត់ សម្លេងសូន្យឈឹងភ្លាម ក្នុងខណៈដែលធ្រឹស្តទ្យុម័ន ជាព្រះ

អនុជរបស់នាងទ្រៅបទី សូត្រប្រកាសតាមប្រពៃណីថា៖

«ព្រះអង្គម្ចាស់ក្សត្រីទ្រៅបទី ទ្រង់មានឆោមឆើតឆាយមកឈរនៅទីនេះ បើអ្នកណាអាចយឹតធ្នូនេះបាន ហើយបាញ់រហូតដល់កងចក្រដែលកំពុងតែវិលខ្វាល់ទៅត្រូវចំភ្នែកត្រីមាស ខាងលើឯណោះ បើអ្នកនោះឯងជាដៅពង្សអ្នកជាសោត នឹងបាននាងជាបាទបរិចារិកា» ។

សូត្រប្រកាសចប់ស្រេចហើយ ក៏ទ្រង់សូត្របញ្ជីរាយនាមវង្ស និងប្រវត្តិដោយសង្ខេប ពណ៌នាគុណសម្បទនៃក្សត្រិយ៍ទាំងអម្បាលនោះឲ្យនាងស្តាប់ ហើយសុំឲ្យនាងយកភួងមាល័យទៅបំពាក់អ្នកដែលបាញ់ត្រូវវង់ តាមសេចក្តីប្រកាសមកហើយ ។

លំដាប់នោះ ក៏ចាប់ផ្តើមប្រឡងធ្នូសិល្ប៍រើសស្វាដៃពួកក្សត្រិយ៍ទាំងអស់នោះ អង្គខ្លះនឹករាក្នុងព្រះទ័យ ព្រោះមើលទៅឃើញមហាធ្នូដ៏សម្បើម និងវង់ដែលប្រុងតែនឹងគេចពីព្រួញធ្នូ គិតថាបើទុកជាអ្នកណាចេះធ្វើម្តេចក៏បាញ់មិនត្រូវដែរ សូម្បីឲ្យគ្រាន់តែយឹតធ្នូបានប៉ុណ្ណោះ ក៏ចាត់ថាជាអ្នកវិសេសណាស់ទៅហើយ ។ ក្សត្រិយ៍ទាំងឡាយចូលទៅប្រឡងម្តងមួយអង្គ ៗ រួចហើយក៏ត្រឡប់មកគង់តាមកន្លែងដើមវិញ ដោយមិនវិសេសប្លែកអ្វីជាងគ្នា ធ្វើឲ្យតែអ្នកអង្គុយចាំមើលលបអស់សំណើចលេង ។ ឯសាមីខ្លួនមានតែសេចក្តីទោមនស្សតូចចិត្តពន់ប្រមាណ ដោយខុសពីគំនិតដែលគិតទុកមកនោះ បែរជាមិនសមដូចបំណងទៅវិញ ទឹកព្រះភ័ក្ត្រឡើងមិនស្រួលតែរាល់អង្គ ។ ពួកអ្នកចម្បាំងដែលធ្លាប់ល្បីឈ្មោះទាំងប៉ុន្មាន កាលបើចូលទៅជិតមហាធ្នូហើយ ក៏បណ្តាលឲ្យស្លុតរន្ធត់ចិត្ត ឡើងទឹកមុខស្លេកស្លាំង មិនអាចនឹងលើកមហាធ្នូនោះរួចឡើយ អ្នកខ្លះចូលទៅជិតបែបដូចជាខែងវែងសង្ហាជាងគេ ដោយអំណាចមានះខំធ្វើឫកពាឡើង ប៉ុន្តែគង់មិនប្លែកអ្វីជាងអ្នកមុន ៗ ដែរ បែរជាត្រឡប់មកអង្គុយនៅកន្លែងដដែលវិញ ។ អ្នកដែលធ្វើការប្រឡងមិនបានសម្រេចទាំងនោះ ខ្លះក្លែងធ្វើទឹកមុខឲ្យរីករាយ ដើម្បីកែសេចក្តីអៀនខ្មាសក្នុងចិត្ត ខ្លះក្លែងធ្វើជាញញឹមបែបស្ងួត ៗ ។



លំដាប់នោះ កណ៌ជាមនុស្សពូកែយ៉ាងចំណាប់ដើរចូលទៅដល់ទីមហាធ្នូ ចាប់យឹតតម្លោះធ្នូ មកបានភ្លាម ។ ព្រះបាទទ្រុបទ និងព្រះឱរសក៏នឹកស្ញើច, ក្នុងព្រះហឫទ័យ ក្រែងកណ៌ មនុស្សដែលព្រះអង្គមិនស្គាល់ជាតិកំណើតជាដូចម្តេច ធ្វើការបានសម្រេច ប៉ុន្តែមុននឹងបាញ់ព្រួញចេញទៅ នាងទ្រៅបទី បានស្រែកប្រកាសសេចក្តីបំណងរបស់នាងថា នាងមិនសព្វព្រះហឫទ័យនឹងកណ៌ ដ៏ជាបុត្រនាយសារថីទេ ។ កណ៌ចេញស្លក់ទឹកមុខ មានក្រសែឈាមទោសៈឡើងព្រួល ៗ ទម្លាក់ធ្នូចុះហើយ ក៏ត្រឡប់មកអង្គុយដូចដើមវិញ ។

នៅមានអ្នកចូលទៅធ្វើការប្រឡងប្រជែង ក្រោយកណ៌ទៀតជាច្រើននាក់ បានប្រឹងប្រែងក្លែងធ្វើមានះខែងវែងណាស់ដែរ ក៏ប៉ុន្តែ

មិនបានសម្រេចដូចបំណងសោះ អ្នកខ្លះខិតខំជ្រុលហួសកម្លាំងពេក ទាល់តែភ្លាត់ចំណាប់ដួលដេកចង្ហែងលើផែនពសុធា ។ បណ្ដាអ្នកអង្គុយមើលទាំងប៉ុន្មានក៏នាំគ្នាសើចលាន់ ដោយឃើញថាជារឿងគួរឲ្យអស់សំណើចណាស់ ។

ពួកបាណ្ឌពកុមារដែលអង្គុយនៅក្នុងអំឡុងពួកព្រាហ្មណ៍ឃ្លាតពួកក្សត្រិយ៍ទៅបន្តិច អង្គុយមើលគេធ្វើឫកព្រងើយកន្តើយហាក់បីដូចគ្មានកិច្ចការអ្វីជាប់ជាមួយនឹងគេក្នុងថ្ងៃនោះសោះ ។ ខណៈនោះ មាណពរូបឆោមស្រស់ប្រិមប្រិយម្នាក់ក្រោកដើរចេញមកអំពីចំណោមពួកព្រាហ្មណ៍ទាំងនោះ ។ បណ្ដាអ្នកប្រជុំនៅទីនោះក៏នាំគ្នាសើចឃឹក ៗ ពេញទាំងព្រះលានហ្លួង ព្រោះនឹកអស់សំណើចក្នុងចិត្តថា ព្រះ[១]អ្នករៀនសូត្រតែខាងធម្ម ធម្មោ ម្ដេចក៏ហានក្លាចូលមកប្រកួតប្រណាំងអួតថ្វីដៃតតាំងនឹងក្សត្រិយ៍ជាតិអ្នកចម្បាំងដែរ ។ អាស្រ័យហេតុនោះ ព្រាហ្មណ៍ខ្លះដែលអង្គុយនៅទីនោះ និយាយឃាត់ខាំងព្រាហ្មណ៍កំលោះ អ្នករួមភេទជាមួយគ្នានោះថា «កុំទៅប្រឡងនឹងគេអី» ។ អ្នកខ្លះនិយាយថា «ជាតិព្រាហ្មណ៍តែងតែមានថ្វីដៃគ្រប់យ៉ាង ទាំងការគិតអាន ទាំងការប្រើអាវុធផ្សេង ៗ មិនមែនចេះដឹងតែត្រឹមរឿងសីលពរប៉ុណ្ណោះទេ» ។ អ្នកខ្លះគ្រាន់សម្លឹងមើលព្រាហ្មណ៍កំលោះនោះដោយសេចក្ដីនឹកអស្ចារ្យ ឥតស្រដីថាអ្វី ។ ឯ

១)- ពាក្យនេះសម្រាប់ហៅព្រាហ្មណ៍ អ្នកសិក្សាក្នុងផ្លូវសាសនាព្រាហ្មណ៍ ។



ព្រាហ្មណ៍កំលោះ ក៏ដោះអស់គ្រឿងប្រដាប់សម្រាប់យោគី ដែលធ្វើដោយស្បែកម្រឹគចេញពីខ្លួនអស់ ហើយគរទុកនៅកន្លែងម្ខាងរួចស្រេច ដើរចូលទៅត្រង់កណ្ដាលស្នាមរណរង្គហាក់ដូចរាជសីហ៍ គន់មើលទៅទ្រូង និងស្មាធំសាយទូលាយ ត្រង់ចង្កេះមូលក្លំវាសុទេវិនដើរប្រទក្សិណព្រមទាំងភាវនាតែក្នុងចិត្ត ។ ចំណែកឯភ្នែករបស់មនុស្សជាច្រើនពាន់នាក់ សម្លឹងសំពីមើលចំពោះតែឆោមឆើតព្រាហ្មណ៍កំលោះ ។ លំដាប់នោះ ព្រាហ្មណ៍កំលោះ ក៏កែក្រាយចាប់លើកមហាធ្នូឡើងយឹតតម្លោះក្រើត មកដោយកម្លាំងដ៏មហិមារបស់ខ្លួន ។ បណ្ដាអ្នកអង្គុយមើលជុំវិញទីស្នាម ក៏ទះដៃលាន់ផ្ទូង ៗ ប្រុស ៗ នាំគ្នានិយាយសរសើរផ្សេង ៗ ។ ត្រឹមតែយឹតធ្នូទន់មកបានប៉ុណ្ណោះ នៅមិនទាន់ចប់អស់រឿងទេ នៅមានការជាយ៉ាងសំខាន់ជាងនេះទៅទៀតដែលគេត្រូវធ្វើខានមិនបាន គឺគេបាញ់ឲ្យត្រូវចំត្រង់វង់ ។ អ្នកមើលទាំងអស់ ឈប់សម្លឹងមើលឆោមព្រាហ្មណ៍ហើយបែរជានាំគ្នាសម្លឹងសំដៅឆ្ពោះទៅតែត្រង់វង់នោះវិញ លែងដាក់ភ្នែកព្រោះជាវេលាផ្ដាច់ព្រ័ត្រដ៏សំខាន់បំផុតយកឈ្នះយកចាញ់គ្នា នៅវេលាប្រមាណមួយវិនាទីទៀតប៉ុណ្ណឹង[១] ។

គ្រានោះ ព្រាហ្មណ៍ក៏ទម្លាក់ក្រាញកែក្រាយរំពើន ហើយ

១)- ប្រាសាទនគរវត្តនៅព្រះរបៀងទី១ ខាងជ្រុងពាយ័ព្យ មានរូបភាពប្រឡងធ្នូសិល្ប៍ដូច្នេះដែរ ប្លែកគ្នាតែរូបសម្រាប់បាញ់នៅទីនោះ ជារូបសត្វសេកវិញ ។

ស្រងេវនេត្រតម្រង់លែងតម្លោះធ្នូ ខ្ទាប់ចេញទៅ ព្រួញរត់រ៉ុទៅប្រហារភ្នែកត្រីមាសធ្លាក់ចុះដល់ធរណីមួយរំពេច ។ ខាងអ្នកមើលក៏ទះដៃប្រែស ៗ លាន់ឮទាំងស្នាមធំ ។ អ្នកដែលមានជ័យនោះ ទោះបីជាអ្នកណាក៏ដោយចុះ គេលែងត្រូវការនឹងគិតនឹកយកមកជាអារម្មណ៍ហើយ គេត្រូវការតែខាងសប្បាយជាការធំដុំវិញ នឹងត្រូវការឲ្យដឹងតែត្រង់ផលជាទីបំផុតនៃការនោះ ដែលកំពុងតែឃ្លានដឹងរាល់គ្នា គឺបាញ់ត្រូវ ឬមិនត្រូវតែប៉ុណ្ណោះ ។

ប៉ុន្តែ កាលណាពួកក្សត្រិយ៍អ្នកទ្រង់ព្រះមាលា សៀតរោមសត្វ ឬទ្រង់ឈ្នួត យាងតម្រង់ទៅត្រង់ទីធ្នូសិល្ប៍ម្តង ១ នោះទ្រូងនាងទ្រៅបទី ក៏ជ្រួលច្របល់ច្រាលឡើងកាលនោះ ។ ត្រីមាសដែលគេព្យួរតែងតោងលើកងចក្រ ជាគ្រឿងសំគាល់យថាកម្មរបស់នាងនោះឥឡូវនេះ នាងក៏កាន់តែរីករាយសប្បាយក្នុងព្រះហឫទ័យខ្លះហើយ ព្រះទ័យរបស់នាងស្ទុះទៅចាប់ប្រតិព័ទ្ធនឹងប្រុសកំលោះ ដែលមានស្បែកខ្លាជាគ្រឿងដណ្តប់កាយនោះ តាំងពីគេឈានជើងដើរចូលទៅត្រង់កណ្តាលទីស្នាម នាងក៏នឹកស្នេហាជាងក្សត្រិយ៍ទាំងឡាយដែលទ្រង់ព្រៃពណ៌ស្វាយ ទោះបីនាងមិនបានគិតទុកជាមុនថា ប្រុសកំលោះនឹងចូលមកធ្វើការប្រកួតថ្វីដៃនឹងគេក៏ពិតមែន ប៉ុន្តែនៅវេលាដែលគេឈរកណ្តាលស្នាមប្រុងប្រៀបនឹងធ្វើការប្រឡងនោះ ព្រះទ័យរបស់នាងរំជួល ដោយចង់ឲ្យគេបានទទួលសេចក្តីអំណរ វេលា



នេះ ក៏បានសមដូចមនោរថរបស់នាងហើយ នាងញញឹមដោយអារម្មណ៍ដ៏រីករាយ ទើបយាងយាត្រាទៅរកអ្នកដ៏មានជ័យជម្នះដោយរួសរាន់ យកភួងមាល័យទៅបំពាក់ឲ្យប្រុសកំលោះ ជាគ្រឿងប្រកាសសិទ្ធិយ៉ាងដាច់ខាតថា ប្រុសកំលោះនេះជាគូភិរម្យរបស់នាងបីដូចជាប្រថាប់ដោយព្រះវរលញ្ឆករ ។

នៅវេលាដែលនាងទ្រៅបទី យកភួងផ្កាទៅបំពាក់ឲ្យអ្នកមានជ័យនោះ បណ្តាអ្នកដែលរួចការប្រឡងជាមួយគ្នា ប៉ុន្តែមិនបានសម្រេចដូចប្រាថ្នា នាំគ្នាមកអង្គុយជូតញើស បានឃើញនាងទ្រៅបទី យកភួងផ្កាទៅបំពាក់ឲ្យអ្នកមានជ័យដូច្នោះហើយ កើតចិត្តឫស្យា ឈឺចាប់រោលរាលខ្លាំងណាស់ នឹងទប់ទល់អាត្មាពុំបាន ក៏ប្រឹក្សាយល់ឃើញព្រមគ្នាថា ត្រូវតែសម្លាប់អ្នកមានជ័យ ដែលមិនប្រាកដនាមនេះចោលមួយរំពេចជាដាច់ខាត បើទុកឲ្យរស់នៅតទៅទៀត មុខជានឹងកើតសេចក្តីអប្បយសដល់គេឯងរាល់គ្នា ដ្បិតវាជាស្មូមយាចក ដើរតែសូមទានគេតាមថ្នល់ ហើយវាមកបានធីតាក្សត្រិយ៍ជាបាទបរិចារិកាដូច្នេះ ធ្វើឲ្យអាម៉ាសមុខ ធ្វើឲ្យអាប់ឱនកិត្តិយស ព្រោះវាមកមើលងាយរាជត្រកូលកំពូលឥស្សររបស់យើង យើងត្រូវឃុំខ្លួននាងទ្រៅបទីទុក ព្រោះជាស្រីឥតខ្មាស ដាក់ខ្លួនបន្ទាបត្រកូល សុខចិត្តយកព្រាហ្មណ៍អនាថាធ្វើជាភស្តា មើលងាយបារមីព្រះបិតា និងព្រះរាជាទាំងឡាយដ៏ជារាជាសម្ព័ន្ធមិត្រ សឹងទ្រង់នូវ

កិត្តិយសដ៏ខ្ពង់ខ្ពស់ យើងរាល់គ្នានឹងមើលបំណាំតទៅទៀត ឃើញជាពុំបានឡើយ ។ លុះប្រឹក្សាយល់ព្រមគ្នាភ្លាម ក៏ស្រែកគំរាមលាន់រំពងដោយសេចក្ដីក្រោធខ្លាំងណាស់ ពួកក្សត្រិយ៍អ្នកប្រឡងធ្នូសិល្ប៍ទាំងប៉ុន្មានអង្គ ក៏លោតចេញអំពីទីកន្លែង រាំក្រឹទន្ទេង ចូលទៅរកព្រាហ្មណ៍កំលោះ ដែលបាននាងជាបំណាច់ថ្វីដៃ កើតការតស៊ូគ្នាឡើងជាកោលាហល គ្មានអ្នកណាអាចនឹងឃាត់ឃាំងឲ្យស្ងប់រម្ងាប់បាន ការស្វយម្ពរក្លាយទៅជាការកាប់សម្លាប់គ្នាកណ្ដាលស្នាមធំ ។ ក្សត្រិយ៍ទាំងឡាយដែលមកប៉ុនប៉ងយកមឲ្យបាននាងទ្រៅបទីត្រ-ឡប់ទៅជាមកដេកបម្រះនឿលលើផ្ទៃពសុធា នាំគ្នាចូលក្នុងអន្ទាក់ម្ឆ្យុរាជដោយអង្គីហេតុដ៏គួរសម ។ កណ៌ជាអ្នកល្បីនាមចូលប្រឡងយុទ្ធនឹងពួកព្រាហ្មណ៍អ្នកមានជ័យ តទល់គ្នាយ៉ាងរមួតអស់វេលាយ៉ាងយូរ, មួយចាក់, មួយចាប់, មួយកាប់. មួយកាត់, មួយកែង មួយគេច, កែក្រាយរារង, មួយរុក មួយរុញ សង្គុញចូលជិត សង្សកពោមរឹតរោរាំខ្ទង់ កលបីដូចជាខ្យល់កំបុតត្បូង ប្រហារត្រូវដៃជើងព្រាហ្មណ៍ដោយព្រួញធ្នូជាច្រើនអន្លើរាប់ថាជាអ្នកបាញ់ត្រង់គ្រាន់បើដែរ ។

ទ្រៅបទីនៅវេលានោះ នាងជាទុក្ខតឹងទ្រូងពេកណាស់ នឹងប្រទេចផ្កាសាមតិកនៃសេចក្ដីលំអោមរបស់នាងតែក្នុងចិត្ត ដែលជាហេតុឲ្យកើតការកាប់សម្លាប់គ្នា លោហិតប្រាលរន្ទាលពាសពេញស្នាម ប៉ុន្តែកន្លងមកបន្តិច នាងក៏រម្ងាប់ទុកនោះបាន ដោយគិតឃើញ



ថា ខ្លួននាងគ្មានមន្ទិលសៅហ្មងអ្វីសោះ មួយទៀត ជីវិតរបស់ប្រុសដែលជាគូវាសនារបស់នាងសោត ក៏ប្រាសចាកអន្តរាយ ដ្បិតវេលានេះ កណ៌ឈប់តស៊ូហើយ ។ ចំណែកកណ៌ដែលបានជាឈប់តស៊ូនោះ ដោយគិតឃើញថា បើពួកគេខំតែតស៊ូទៅ មុខជានឹងស្លាប់ក្នុងកណ្ដាប់ដៃព្រាហ្មណ៍កំលោះនេះមិនខាន គិតដូច្នោះហើយ គេក៏ស្រែកសួរព្រាហ្មណ៍នោះ ជាផ្លូវញ៉ែមខ្លាចថ្វីដៃថា «ម្នាលលោក ! លោកជាត្រកូលព្រាហ្មណ៍មែនឬ ? តែឋានៈ និងមានះរបស់លោកសម្ដែងឲ្យឃើញថា ខ្លួនលោកមិនមែនជាត្រកូលព្រាហ្មណ៍ទេ ព្រោះមិនដែលមានព្រាហ្មណ៍ឯណា ជាអ្នកមានថ្វីដៃអាចមកតដៃនឹងក្សត្រិយ៍បានឡើយ វៀរលែងតែបរសុរាម (រាមេសូរ) ដែលប្រាកដតាមបរម្បរគតិថា បានប្រហារក្សត្រិយ៍ទូទៅក្នុងលោក ឯស្មូមយាចកអនាថាធ្លាប់តែដើរសូមទានគេរាល់ផ្ទះ រាល់រានផ្សារ នឹងថាជាអ្នកស្ទាត់ចម្បាំងមិនបាន, ពិតដូច្នេះហើយ បណ្ដាអ្នកចម្បាំងដូចគ្នា គ្មានអ្នកណាមានថ្វីដៃច្បាំងល្អដូចអរជុនទេ ក្នុងពពួកមនុស្សដែលគ្រប់គ្រងជីវិតរស់នៅសព្វថ្ងៃនេះ នឹងតដៃជាមួយយើងបាន ក៏តែអរជុនម្នាក់ប៉ុណ្ណោះ ក្រៅពីនោះគ្មានសោះឡើយ ។

ព្រាហ្មណ៍កំលោះញញឹមតបវិញហើយដើរចូលទៅកាន់ទីកន្លែងដើមរបស់ខ្លួន ឯទ្រៅបទីក៏លីលាតាមគូស្នេហ៍គ្រងរបស់នាងទៅដែរ ។

## ភាគទី ៣

# អាវាហមង្គលនៃនាងទ្រៅបទី

ស្ត្រីអនាថាអាស្រ័យនៅក្នុងរោងនាយស្មូនឆ្នាំង ចាំមើលផ្លូវកូនទាំង ៥ ដែលនាំគ្នាទៅមើលការស្វយម្ពរនាងទ្រៅបទី ។ បុត្រទៅបាត់យូរពេកខុសពេលវេលា នាងនឹកព្រួយក្នុងចិន្តាណាស់ ក្រែងកើតហេតុភេទភ័យឡើងក្នុងស្រុកគេ ។ ខណៈនោះ នាងឮសូរសន្ធឹកជើងដើរចូលមកកាន់រោងដោយរួសរាន់ បន្តិចកូនទាំង ៥ ឈានជើងចូលមកដល់ ទាំងដឹកដៃនាងក្រមុំម្នាក់មកផង សឹងតាក់តែងកាយដោយគ្រឿងប្រដាប់ដ៏វិចិត្រ សុទ្ធតែពេជ្រនិលចិន្តាព្រោងព្រាយ វេលាដែលបែរទៅឃើញនាងធីតាទ្រង់ឆោមឆើតឆាយ សេចក្ដីបីតិត្រេកអរក៏ផ្សាយសព្វសព៌ាង្គរាងកាយ នាងគ្រាន់តែក្រឡេកឃើញភ្លាម ក៏នឹកដឹងរឿងរហូត ។ មាតា និងបុត្រសន្ទនាអាស្រ័យគ្នាតាមទំនៀម ។ ព្រះរាជកុមារទាំង ៥ អង្គក៏ទូលរៀបរាប់រឿងសិទ្ធិជោគ ដែលខ្លួនធ្វើការមានថ្វីដៃ ឲ្យព្រះជននីស្ដាប់ តាំងពីដើមដល់ចប់ចុង ។

តពីនេះទៅ នឹងសម្ដែងពីហេតុការណ៍ដែលប្រព្រឹត្តទៅក្នុងព្រះរាជវាំងក្រុងបញ្ចាល ។ ព្រះរាជាទ្រុបទ គង់ក្នុងបន្ទប់ក្រឡាព្រះបន្ទំតែមួយព្រះអង្គ យូរបន្តិចស្រាប់តែស្ដេចទ្រង់ក្រោកឡើងតូងតាងធាក់អ្នកនេះ អ្នកនោះ ដែលនៅជិតបក់ផ្លិតថ្វាយ ។ ខណៈនោះ ព្រះ



ឱរសចូលទៅគាល់ក្នុងបន្ទប់ មានព្រះភក្ត្រផូរផង់ញញឹមញញែមរីករាយ ។ ព្រះរាជាធ្វើព្រះភក្ត្រតឹងថ្មឹងទៅរកឱរស លុះស្វាងព្រះក្រោធហើយ ត្រាស់សួរថា «ទ្រៅបទីនៅឯណា ? អ្នកណាបាននាង ? ឱកូនសម្លាញ់ឪពុក ! » ព្រះសូរសៀងដែលត្រាស់ចេញមកញ័រហើយស្អកស្អាផង ទ្រង់គង់ស្ងៀមបន្តិច ត្រាស់តទៅទៀតថា ឱកូនស្រីមាសឪពុក ! តាំងពីនេះរៀងទៅ នាងតោងដើរសូមទានគេ ចិញ្ចឹមពោះ រាល់មាត់ទ្វារផ្ទះអ្នកដទៃ, រាល់វត្ថុដែលគេលះបង់ឲ្យ ដោយការុណ្យចិត្ត និងប្រណីនេះឯង ជារាជបណ្ណាការរបស់នាង, ភាជនៈដែលនាងកាន់ទូលត្រាច់សូមទាននោះ ទុកជាគ្រឿងប្រដាប់ត្បូងរបស់នាង ឱអនិច្ចា ! ឪពុកនឹងទ្រាំអត់សង្កត់ក្ដីទុក្ខវេទនាអស់នេះបានដែរឬទេ ? នៅពេលដែលឪពុកបានឃើញកូនស្រី ស្ពាយយាមលើស្មាដើរសូមទានគេនោះ, ឪពុកបានកសាងកុសលកម្មទុកមកអំពីកាលណា បានជាមកទទួលសេចក្ដីអវសានដូច្នេះ ឱអនិច្ចា ! ឪពុករម្ងាប់ទុក្ខក្នុងរឿងនេះមិនបានទេ ទុកជាខំប្រឹងរម្ងាប់ដូចម្ដេច ក៏នៅតែមិនបាត់ក្រំចិត្តដែរ, ឪពុកអត់សង្កត់ណាស់ ទាល់តែស្គាំងស្គមទ្រមខ្លួន រឿងដែលផុតវិស័យសតិបញ្ញានឹងកែខៃ ឬទាល់អស់ផ្លូវនឹងដើរហើយ ឪពុកនឹងធ្វើម្ដេចកើត ! ឪពុកតាំងចិត្តថានឹងលើកកូនឲ្យទៅអរជុន ប៉ុន្តែព្រះជាម្ចាស់លើស្ថានសួគ៌ មកបណ្ដាលឲ្យឃ្លៀងឃ្លាតទៅជាយ៉ាងដទៃវិញ, ឪពុកដឹងច្បាស់ណាស់ហើយថា «ការយំ

ខ្សឹកខ្សួលមិនជាប្រយោជន៍អ្វីសោះ តែសេចក្ដីសោយសោកនឹងស្ងប់រម្ងាប់ទៅបានដោយគ្មានអារម្មណ៍យ៉ាងសម្លឹកដូច្នេះឬ ? ទុក្ខនេះ ជាមរណទុក្ខរបស់បិតាហើយកូន!» ។

ធ្រិស្ដទ្យុម័ន ក្រាបទូលដោយវាចាទន់ផ្អែមល្ហែមថា «បពិត្រ ព្រះជនកនាថ សូមព្រះអង្គបន្ទោបង់នូវសេចក្ដីសោកអស់នេះ ចេញឲ្យផុតអំពីព្រះកមលចុះ ព្រះករុណា ! អរជុនជាអ្នកបាននាងទៅពិតប្រាកដហើយ» ។

ព្រះរាជាមានព្រះអស្សុជលកំពុងតែហៀរហូរ ក៏ស្ងួតស្ងាងថៃសភ្លាម ដោយអំណាចពលវបីតិនៅនាគ្រានោះ ទ្រង់ត្រាស់សួរជាប្រញាប់ថា «មែនឬ! មែនឬ! ឯងដឹងបានដូចម្ដេច ? អើឯងនិយាយទៅមើល!» ។

ព្រះឱរសក្រាបទូលប្រព្រឹត្តហេតុថា «កាលព្រាហ្មណ៍នាំព្រះនាងជេដ្ឋភគិនី ទៅកាន់ទីសំណាក់អាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំបានលបលាក់ខ្លួនតាមពីក្រោយទៅមើលមិនឲ្យគេឃើញ លុះគេចូលក្នុងទីលំនៅរបស់គេ ទូលព្រះបង្គំជាខ្ញុំផ្ទៀងត្រចៀកប្រុងចាំស្ដាប់ពីខាងក្រៅទ្វារ បានឮរឿងនេះយ៉ាងច្បាស់លាស់ក្នុងកាលដែលគេនិយាយរៀបរាប់ឲ្យមាតាគេស្ដាប់ បានជាទូលព្រះបង្គំដឹងថាព្រាហ្មណ៍មួយពួកមានគ្នា ៥ នាក់ ស្លៀកពាក់ស្បែកម្រឹគនោះ គឺជាបាណ្ឌពកុមារ បងប្អូនទាំង ៥ អង្គក្លែងខ្លួនបន្លំចូលមក មុខគួរឲ្យ



អាណិតអាសូរពេកណាស់ បាណ្ឌពកុមារ និងមាតា បានសេចក្ដីទុក្ខព្រួយលំបាកជាទីបំផុត ព្រោះទុរយោធន៍គិតឫស្យាដុតបំផ្លាញមន្ទីររបស់គេ បំណងនឹងឲ្យគេស្លាប់ក្នុងគំនរភ្លើង ប៉ុន្តែគ្រោះជា បាណ្ឌពកុមារបានដឹងខ្លួនជាមុន ទើបនាំគ្នារត់ទៅតាមផ្លូវបាតាល គេចរួចអំពីអគ្គីភ័យមក បានបបួលគ្នាដើរផ្លូវមកជាមួយនឹងពួកព្រាហ្មណ៍ទាល់តែមកដល់ក្រុងបញ្ចាលនេះ» ។

ព្រះរាជាទ្រង់ជឿជាក់ឥតសង្ស័យ ទើបត្រាស់ថា «កូនឯងចូរទៅប្រាប់អគ្គមហាសេនាបតី ឲ្យគេទៅស៊ើបសួរយកសេចក្ដីពិតមកឲ្យបាន» ។ ខ្ញុំរាជការមួយក្រុមទទួលព្រះរាជឱង្ការហើយ នាំគ្នាដើរសំដៅទៅផ្ទះស្មូនឆ្នាំង មន្ត្រីទាំងនោះចូលទៅថ្វាយគំនាប់បាណ្ឌព-កុមារ ហើយមានម្នាក់ក្នុងពួកមន្ត្រីដែលទៅនោះ ទូលប្រព្រឹត្តហេតុដល់រាជកុមារដែលបាននាងទ្រៅបទីថា «យើងខ្ញុំនាំគ្នាមកសម្ដែងអំណរដែលទ្រង់មានជោគជ័យ, ការដែលទ្រង់សម្ដែងស្នាដៃក្នុងនេះពួកអ្នកចម្រៀងនឹងចងជាកាព្យទុកសម្រាប់សង្គីតិប្រគំច្រៀង, ពួកចិន្តក្រវីរាជប្រាជ្ញពង្សាវតារនឹងចារិករឿងនេះទុកក្នុងពង្សាវតារ ឲ្យល្បីខ្ចរខ្ចាយទូទៅ, និករជាតិទាំងឡាយ ក៏នឹងមនសិការចាំទុករហូតកល្បាវសានដោយឆន្ទៈនិយម, កាលក្សត្រិយ៍ទាំងឡាយបាញ់មិនត្រូវវង់នោះ ខន្តិយាធិបតីរបស់យើងព្រួយព្រះហឫទ័យថា ព្រះរាជធីតារបស់ព្រះអង្គត្រូវនៅជាលីវសាវកែរកគូគ្មានអស់មួយជីវិត» ។

រឿងនេះជាទុក្ខធំគ្របសង្កត់ព្រះហឫទ័យ ប៉ុន្តែឥឡូវយើងខ្ញុំសូមទទួលអំណរគុណទ្រង់យ៉ាងខ្ពង់ខ្ពស់ ដែលទ្រង់បានកំចាត់បង់មេក្រមី ពោលគឺសេចក្តីកង្វល់ដ៏ធំ សឹងគ្របសង្កត់ព្រះហឫទ័យនៃព្រះករុណាឲ្យខ្ចាត់ចេញទៅបាន ប៉ុន្តែតាមការពិតវិញ យើងខ្ញុំយល់ឃើញថា ល្មមនាំមកបញ្ចេញចែកចាយគ្នាស្តាប់បានហើយ មិនជាការល្មើសក្នុងកិច្ចរក្សាសេចក្តីស្ងាត់កំបាំង នៅនាព្រះហឫទ័យនោះទេ គឺថាកាលពីដើមមក ទ្រង់ប៉ុនប៉ងនឹងប្រទានធីតាទៅអរជុនជាអ្នកដែលល្បីល្បាយនាមទូទៅទាំងសកលជម្ពូទ្វីបឲ្យបានធីតារបស់ព្រះអង្គ លុះដល់វេលានេះទ្រង់មានព្រះទ័យបីតិយ៉ាងលើសលន់ ព្រោះព្រះធីតាមិនបាននៅជាសីវសាវកែទេ ព្រះអង្គឆ្ងល់ខ្ងល់ព្រះហឫទ័យជាពន្លឹកដោយចង់ជ្រាបជាតិ ត្រកូល និងស្រុកកំណើតរបស់អ្នកមានជ័យ រហូតដល់វេលាដែលបានដឹកដៃនាងទ្រៅបទី ព្រះរាជធីតាមកនេះ ។

បាណ្ឌពរាជកុមារអង្គធំ គឺយុធិស្ឋិរ ទទួលភារៈនិយាយតតបទៅនឹងពួកខ្ញុំរាជការ ដែលមកនោះដោយព្រះអង្គឯង ទ្រង់មានព្រះបន្ទូលថា «សេចក្តីសន្យាអំពីការស្វយម្ពរ ដែលស្តេចដ៏ទ្រង់នូវឥស្សរស័ក្តិយ៉ាងខ្ពង់ខ្ពស់របស់អ្នកទាំងឡាយ បានប្រកាសហើយនោះ អ្នកទាំងពួង និងយើងទាំងអស់គ្នា ក៏បានជ្រួតជ្រាបសព្វគ្រប់ហើយ អ្នកណាក៏អាចចូលទៅប្រឡងល្បងមើលថ្វីដៃបានគ្រប់ ៗ គ្នាដែរ បណ្តា



អ្នកដែលទៅក្នុងទីនោះ, ឯសេចក្តីសន្យានោះ សុភាពបុរសនេះឯងបានប្រតិបត្តិត្រឹមត្រូវហើយ ព្រោះហេតុនេះ ព្រះធីតាដ៏ជាម្ចាស់របស់អ្នកទាំងឡាយ ទើបបានជាគូភិរម្យរបស់គេ ទោះបីអាក្រក់ ឬល្អក៏គាមតែយថាកម្មចុះ» ។

ពួកខ្ញុំរាជការទាំងនោះចេញទឹកមុខងឿងឆ្ងល់ ។ យុធិស្ឋិរមិនចង់ឲ្យខ្ញុំរាជការទាំងនោះងឿងឆ្ងល់សោះ ទើបពោលតទៅទៀតថា «មនុស្សទូទៅគ្មានអ្នកណាម្នាក់ឡើយនឹងសង្ស័យថា អរជុនជាអ្នកចម្បាំងដ៏ឯករកគូប្រៀបគ្មាន ហើយមិនត្រូវសង្ស័យតទៅទៀតថាប្រាកដជាអរជុន មិនមែនអ្នកដទៃអំពីណាទេ ដែលបានព្រះធីតាដ៏ជាម្ចាស់របស់អ្នក, យើងសូមសម្តែងសេចក្តីគាប់ចិត្ត និងអនុមោទនាដល់ចៅហ្វាយរបស់អ្នក ដែលបានឃើញការសម្រេចផលសមប្រាថ្នានូវរបស់ដែលគិតទុកមកជាយូរយារហើយនោះ» ។

កាលពួកខ្ញុំរាជការបានស្តាប់ដូច្នេះហើយ ក៏ក្រោកឡើងព្រមគ្នាថ្វាយគំនាប់ ដោយឱនលំទោនរួចលាចេញទៅ ។ សេចក្តីបំណងរបស់គេក្នុងវេលានេះ ក៏បានសម្រេចពិតប្រាកដឥតសង្ស័យ ដោយល្បួងសួរយកការណ៍ពិតទាល់តែបាន តាមសេចក្តីដែលម្ចាស់ជីវិតប្រើមក គេក៏រីករាយសប្បាយចិត្តណាស់ នាំគ្នាត្រឡប់ទៅក្រាបទូលប្រព្រឹត្តហេតុដល់ព្រះរាជាវិញថា «ការដែលទ្រង់ត្រាស់ប្រើទៅនោះឥឡូវបានសម្រេចដូចព្រះរាជហឫទ័យ ដែលប៉ុនប៉ងហើយ» ។

កាលព្រះរាជាបានជ្រាបសេចក្ដីតាមដែលទ្រង់ត្រាស់ប្រើឲ្យទៅស៊ើបហេតុការណ៍ក្នុងជាន់ក្រោយនេះហើយ គ្រានោះទ្រង់ត្រាស់ឲ្យលេងមហោស្រពក្នុងព្រះរាជមន្ទីរ និងទ្រង់ត្រាស់ឲ្យទៅអញ្ជើញបាណ្ឌពកុមារទាំង ៥ អង្គចូលមកគាល់ ។ មានការរៀបចំទទួលតាមខត្តិយប្រពៃណីក្នុងទីសម្រាប់ទទួលមុខមន្ត្រី ទ្រង់ចូលទៅឱបព្រះឱរសសុណិសា និងព្រះជេដ្ឋកនិដ្ឋាទាំង ៨ អង្គទៀតតាមលំដាប់ ទ្រង់ត្រាស់សុន្ទរកថាទទួលសម្ព័ន្ធមិត្រមេត្រី និងទទួលជានាការពារសព្វភ័យទាំងឡាយក្នុងរាជធានីរបស់ព្រះអង្គ មិនឲ្យមានមោះមន្ទិលប្លោះការបាន ។

លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់ឲ្យចាត់ការស្វយម្ពរវិវាហមង្គលព្រះរាជធីតាទ្រៅបទី ឲ្យសមស័ក្តិ ឲ្យសមកិត្តិយសនៃខត្តិយធីតាគ្រប់ប្រការទាំងឲ្យមានការលេងល្បែងតាមទំនៀមវិវាហៈស-មោទ្យ ។ ឯពួកបាណ្ឌពកុមារ ក៏ដោះគ្រឿងក្លែងក្លាយបន្លំពីព្រះអង្គចេញ ហើយគង់នៅជាសុខក្នុងអារក្ខារបស់ព្រះបាទបញ្ចាលរាជជារាជសម្ព័ន្ធមិត្រដ៏ស្មើចិត្តនោះ ។



## ភាគទី ៤

# ពិធីប្រជុំរដ្ឋមន្ត្រី

កាលព្រះនាងទ្រៅបទីអភិសេកសមរសជាមួយអរជុន រាជកុមារស្រេចហើយ បាណ្ឌពក្សត្រិយ៍ក៏គង់នៅជាសុខសាន្តក្នុងអំណាចអារក្ខានៃព្រះបាទបញ្ចាលរាជ ។ ការគ្រប់គ្រងរក្សាយ៉ាងនេះជាទីគាប់ព្រះទ័យនៃបាណ្ឌពក្សត្រិយ៍ណាស់ ព្រោះទុរយោធន៍បានឃើញហើយចាំច្បាស់ណាស់ថា រាជកុមារអម្បាលនេះ មានជីវិតរស់នៅឡើយ ទុរយោធន៍មុខជាភ្ញាក់ខ្លួនមិនតិចទេក្នុងគ្រាឃើញបាណ្ឌពក្សត្រិយ៍មានជីវិតរស់នៅក្នុងលោក ហើយមុខជានឹកឆ្ងល់ក្នុងព្រះទ័យយ៉ាងខ្លាំង ត្រង់បានឃើញអរជុនមានជ័យ បាននាងក្សត្រិយ៍បញ្ចាលជាបាទបរិចារិកា ។ ទោសចិត្តឫស្យារបស់ទុរយោធន៍មុខជាឆួលឆេះឡើងរកទីបំផុតគ្មាន ត្រង់បានឃើញព្រះញាតិដែលព្រះអង្គធ្វើឧបាយនឹងបំផ្លាញឲ្យវិនាសក្នុងភ្លើងនោះ ហើយបែរជាមកចងស្ពានមេត្រីនឹងព្រះបាទទ្រុបទ ជាសត្រូវជាមួយព្រះអង្គតាំងពីកាលណាមកហើយនោះទៅវិញ ។

មានការប្រជុំធំនៅក្រុងហាស្តិនបុរ ធ្រឹតរាស្ត្រគង់លើរាជបល្ល័ង្កមានរាជបរិពារឈរព័ទ្ធជុំវិញត្រៀបត្រា បីដូចជាផ្កាយចោមរោមព្រះចន្ទ្រ ស្ងាត់សម្លេងជ្រៀប ប្រុងស្ដាប់ស័ព្ទព្រះរាជាតម្រាស់ ព្រះរាជាក៏

ទ្រង់ក្រោកឈរឡើង មានព្រះរាជឱង្ការសូរសីហនាទថា «ម្នាលមុខមន្ត្រីទីប្រឹក្សាទាំងសម្លាយដែលចូលមកសន្និបាតក្នុងទីនេះ សុទ្ធតែជាអ្នកដែលយើងទុកចិត្តក្នុងការផែនដី អ្នកទាំងឡាយជាគោលសិលារបស់ប្រទេស, អាណាចក្ររបស់យើងដែលនឹងតាំងនៅបានក៏ព្រោះអាស្រ័យតែអ្នករាល់គ្នាជាភ្នែកជាច្រមុះ, សេចក្តីចម្រើនរុងរឿងថ្កើងកេរ្តិ៍ និងសេចក្តីសុខសម្រាន្តរបស់រាស្ត្រ ដែលនឹងវឌ្ឍនាការតទៅបាន ក៏ព្រោះអាស្រ័យអ្នកទាំងឡាយ, សេចក្តីសត្យសុចរិតនិងផែនដីនៃអ្នករាល់គ្នា ក៏គ្មានផ្លូវឲ្យរង្កៀសដែរ, ការដែលអ្នកទាំងឡាយភក្តីនឹងយើង ក៏គ្មានមន្ទិលសៅហ្មងសូម្បីប៉ុនល្អងធូលី របស់មោះហ្មងឆ្គងរាគីក៏គ្មានចូលមកលាយឡំក្នុងសាច់ធាតុ ពោលគឺសេចក្តីភក្តីនេះឡើយ, យើងឲ្យហៅអ្នកទាំងឡាយមកប្រជុំក្នុងគ្រានេះ ដើម្បីឲ្យអ្នករាល់គ្នាជួយពិគ្រោះប្រស្នាមួយមុខជាប្រស្នាស្មុគស្មាញណាស់ បើតាមទំនើងវិចារណញ្ញាណរបស់យើងតែម្នាក់ឯងមិនអាចនឹងទំពាឲ្យបែកល្អិតល្អោចបានឡើយ សូមប្រើជាញាណរបស់អ្នករាល់គ្នាជួយទំពាយើងផង សូមឲ្យអ្នកទាំងអស់សម្តែងសេចក្តីភក្តីចំពោះយើង និងចូរជួយបំពេញកិច្ចការផែនដីក្នុងគ្រានេះម្តងទៀត, អ្នកទាំងពួងក៏បានជ្រាបស្រាប់មកហើយថា ពួកបាណ្ឌពបានចងសម្ព័ន្ធមេត្រីនឹងព្រះរាជាទ្រុបទ ដែលធ្លាប់ជាសឹកសត្រូវនឹងយើងពីដើមមកហើយ យើងគិតធ្វើដូចម្តេចទើបនឹងរំលើងរំលាង



អមិត្រដែលគិតប្រទូសរ៉ាយឲ្យផុតចេញពីភយន្តរាយបាន យើងធ្វើយ៉ាងណាឲ្យបានស្រួល ?» ។

ទុរយោធន៍ក្រោកឈរឡើងដោះស្រាយប្រស្នាជាដំបូងថា «សេចក្តីយល់របស់ទូលព្រះបង្គំជាខ្ញុំក្នុងរឿងនេះ គឺថាត្រូវឲ្យស្ទូកពួកសេនាបតីនៃព្រះបាទទ្រុបទ ធ្វើឲ្យបែកសាមគ្គីក្នុងរវាងពួកគេឡើង នេះជាឧបាយម្យ៉ាង, ទូលព្រះបង្គំជាខ្ញុំនៅមានឧបាយក្នុងចិត្តម្យ៉ាងទៀតដែលអាចនឹងឲ្យផលវិសេសជាងឧបាយមុននោះ គឺថាត្រូវរិះរកទោសដ៏លាមក មកបាចប្រឡាក់លើខ្លួននាងទ្រៅបទី ឲ្យទាល់តែនាងនិយាយមិនចេញ ដោះសាកែខ្លួនលែងរួច, ឧបាយនេះជាហេតុធ្វើឲ្យពួកបាណ្ឌពក្រោធខឹងខ្លាំង ហើយលះលែងនាងចោលទៅ បន្ទាប់ពីនោះមក មិត្រភាពរវាងពួកបាណ្ឌព និងបញ្ចាលរាជ ក៏នឹងដាច់ចេញពីគ្នាទៅឯង, ការដែលត្រូវធ្វើបន្តអំពីនោះទៅទៀត គឺថាត្រូវដាក់ថ្នាំបំពុលភីម យក្សធំ ឲ្យស្លាប់បាត់បង់ទៅ, ធ្វើតែប៉ុណ្ណេះមុខជាអស់រឿងអំពល់ចិត្តយើង តទៅទៀតហើយ» ។

ទុរយោធន៍និយាយចប់ហើយអង្គុយចុះ កណ៌ក្រោកឈរឡើងថ្លែងមតិរបស់ខ្លួនថា ៖

«សូមទ្រង់អភ័យទោសដល់ទូលព្រះបង្គំជាខ្ញុំ ក្នុងការដែលមានសេចក្តីយល់ឃើញ មិនស្របដូចទ្រង់ទុរយោធន៍ ដ៏ជាទីសម្លាញ់របស់យើង, ទូលព្រះបង្គំជាខ្ញុំយល់ឃើញថា មានថ្នាំកែតែមួយមុខទេ

គឺថាត្រូវអាស្រ័យកម្លាំងទាហាន ដ៏រឹងឫទ្ធិរបស់យើង សូមឲ្យបញ្ជូនទាហាននេះទៅធ្វើសង្គ្រាមនឹងព្រះបាទទ្រុបទ ជាយ៉ាងឆាប់, ទូលព្រះបង្គំជាខ្ញុំជឿថា កងទ័ពរបស់គេទុរពលភាព មុខជាទប់ទល់នឹងកម្លាំងទាហានរបស់យើងមិនបានទេ បើនឹងលើកកងកម្លាំងទៅយាយីជាន់នេះ ត្រូវតែចាត់ការឲ្យយ៉ាងឆាប់រួសរាន់ដើម្បីកុំឲ្យព្រះក្រឹស្ណៈ, ព្រះរាជាកុសរាជ មានឱកាសលើកកម្លាំងមកជួយគេទាន់»។

លំដាប់នោះ ព្រះបាទធ្ឫតរាស្ត្រត្រាស់សួរភីស្មៈ ក្សត្រិយ៍រាជា តើនឹងមានយោបល់យល់ឃើញដូចម្ដេច ? ភីស្មៈថ្លែងថា «កាលបើព្រះករុណា សូមសេចក្ដីយល់ឃើញរបស់ទូលព្រះបង្គំ ទូលព្រះបង្គំក៏ត្រូវពោលតែពាក្យពិត ប៉ុន្តែចាស់បុរាណលោកថា «ពាក្យពិតវែងស្លែង» ទូលព្រះបង្គំយល់ឃើញថា «តាមសិទ្ធិនៃរាជប្រពៃណី យុធិស្ឋិរជារជ្ជទាយាទ តាមច្បាប់ត្រូវបានរាជសម្បត្តិ បើព្រះករុណាមិនសព្វព្រះរាជហឫទ័យ នឹងលះបង់រាជ្យសម្បត្តិទាំងមូលឲ្យទៅគេទេ ក៏គួរតែបែងចែកផែនដីឲ្យគេពាក់កណ្ដាលដែរ ទើបមានយុត្តិធម៌នឹងសេក្ដីពិត ត្រូវឲ្យទ្រង់ប្រតិបត្តិការក្នុងរឿងនេះដូច្នេះចុះ បើទ្រង់ចេះតែខំកើបកោយយកទ្រព្យសម្បត្តិទាំងភាគដែលគេត្រូវបាននោះមកទៀត ទូលព្រះបង្គំហ៊ានព្យាករទុកជាមុននៅវេលានេះ ថា «សេចក្ដីវិនាសលិចលង់អាណាចក្ររបស់ទ្រង់នឹងមកដល់ក្នុងកាលមិនយូរទេ, សេចក្ដីលោភលន់ហួសប្រមាណនឹងនាំឲ្យកើតនូវសេចក្ដី



វិនាសយ៉ាងធំដល់ប្រយូរវង្សរបស់ទ្រង់ជាមិនខាន ដំណឹងដែលឱរសរបស់ព្រះករុណាគិតប្រទូសរ៉ាយនឹងដុតបងប្អូនទាំងអស់នោះ ល្បីលេចឮចេញទៅរហូតដល់ខាងក្រៅអាណាចក្រកុរុ, អ្នកស្រុកទាំងខាងក្នុង ទាំងខាងក្រៅរាជអាណាចក្រពោលខ្ចាំងខ្ចប់ថា «ទុរយោធន៍ជាអ្នកគិតប្រទូសរ៉ាយទំលាយព្រះញាតិ»។

កណ៌ក្រោកឈរឡើងជាគម្រប់ ២ ដងដើម្បីបរិយាយវចនោវាហាររបស់ភីស្មៈ ថា «ចិត្តរបស់ភីស្មៈប្រកបដោយឆន្ទាគតិ, ភ្នែករបស់ភីស្មៈងងឹតក្នុងយុត្តិធម៌, វិចារណញ្ញាណរបស់ភីស្មៈឃើញឆ្វេងឆេវទៅក្នុងផ្លូវខុស, ភីស្មៈមានពោគាពាធណាមួយមកបិទបាំងញុំាងទស្សនញាណរបស់គេឲ្យវឹកវរទៅ រឿងនេះជាមុខក្រសួងរបស់ទីប្រឹក្សា ទីប្រឹក្សាត្រូវតែដោះស្រាយប្រស្នាឆិតជិតទៅតែម្ដង ដោយទឹកចិត្តដ៏ត្រជាក់ មិនត្រូវញញើតនឹងគ្រឿងខ្ចាំងខ្ចប់ណាមួយឡើយ សំដីទីប្រឹក្សាអ្នកប្រកបដោយសេចក្ដីប្រហែសធ្វេស និយាយចេញមកឃើញថា ខ្សត់ខ្សោយវិចារណញ្ញាណណាស់ មិនគិតឲ្យជុំជិតជ្រុងជ្រោយសិនទេ តែងតែនាំយកសេចក្ដីវិនាសមកឲ្យប្រទេសជាប្រាកដ»។

ទោណាចារ្យឃាត់កណ៌ ថា «ឈប់សិនទៅកណ៌ អើយ ! ឈប់រលាស់អណ្ដាតដែលប្រកបទៅដោយសេចក្ដីអំណួតសិនទៅ អ្នកមិនព្រមបង្អង់និយាយសោះ ទាល់តែសេចក្ដីវិនាសធ្លាក់មកលើខត្តិយ

វង្សរបស់យើងទៅឬអី ? អាការៈធ្ងន់ណាស់ ព្រះគុណអើយ កុំម្លោះពេក ! »។

វិទូរក្រោកឈរឡើង ថ្លែងទទឹងទាស់នឹងមតិទុរយោធន៍ ថា ៖

«មុខងារនាទីរបស់ខ្ញុំ បង្គាប់ខ្ញុំឲ្យលាន់ឮវាចាចេញមកតាមសេចក្ដីពិតត្រង់ក្នុងចិត្ត ដល់ក្នុងទីបំផុតនឹងបង្កើតឡើងដូចម្ដេចលើកទុកមួយអន្លើសិនចុះ ថាបើបណ្ដែតបណ្ដោយឲ្យករណីយហេតុដំណើរការទៅដូច្នេះ មិនយូរប៉ុន្មានទេ មុខជាប្រទះអនិដ្ឋារម្មណ៍មិនខាន, ព្រះនាមាភិធេយ្យនៃវង្សក្សត្រិយ៍របស់យើងនឹងសាបសូន្យបាត់ទៅ ព្រោះហេតុនោះ គំនិតរបស់យើងខ្ញុំថា ត្រូវតែទៅផ្សះផ្សារការបែកសាមគ្គីរវាងព្រះញាតិវង្សដោយឧបាយណាមួយដោយប្រពៃតាមផ្លូវយុត្តិធម៌ទើបគួរ »។

ការប្រឹក្សាគ្នាក៏ឈប់ស្ងៃះតែត្រឹមប៉ុណ្ណេះ ព្រះបាទធ្ឫតរាស្ត្រក៏ប្រកាសកាត់សំនួនជាពាក្យដាច់ខាតចេញមកថា «ត្រូវតែយើងទៅទទួលបាណ្ឌពក្សត្រិយ៍ដែលត្រូវនិរទេស ឲ្យវិលត្រឡប់មកកាន់ព្រះនគរវិញ យើងនឹងប្រគល់ដែនដីហាស្តិនបុរឲ្យពាក់កណ្ដាល ឲ្យបងប្អូនទាំង ៥ សេពសោយសម្បត្តិតាមខត្តិយប្រពៃណីចុះ »។

គ្រានោះ ទ្រង់ចាត់រាជទូតនាំព្រះរាជសាសន៍ទៅកាន់ក្រុងបញ្ចាលដើម្បីនឹងអញ្ជើញយុធិស្ឋិរ ព្រមទាំងព្រះអនុជ ៤ អង្គឲ្យត្រឡប់ព្រះនគរវិញ ។ កាលរាជទូតទៅដល់ក្រុងបញ្ចាលនាំគ្នាចូល



គាល់ក៏ប្រទះនឹងបាណ្ឌពក្សត្រិយ៍ កំពុងតែគាល់សន្ទនាវិករាយជាមួយព្រះទ្រុបទ ។

ព្រះរាជាទ្រុបទ ត្រាស់ព្រះសូរសៀងយ៉ាងអាណោចអាធ័មថា «យុធិស្ឋិរគ្មានរឿងអ្វីក្នុងពង្សាវតាររបស់លោក ដូចជារឿងរបស់អ្នកទេ មុខគួរឲ្យទេវនាម្ល៉េះ ដែលព្រះញាតិរបស់អ្នកត្រឡប់ទៅជាសត្រូវជាគូចងពៀរវារាទឹងគ្នាយ៉ាងនេះ »។

យុធិស្ឋិរថ្លែងថា «អាំ ! រឿងលាភ, រឿងអំណាច ខ្ញុំព្រះបង្គំស្អប់ហើយ មិនចង់ឲ្យឃើញមុខវាទេ វាធ្វើឲ្យបងប្អូនទាស់ទែងគ្នា, ទ្រព្យសម្បត្តិ, អំណាច, ស្ត្រី របស់ ៣ មុខនេះជាមារសម្រាប់ផ្ចាញ់មនុស្សយើងឲ្យចាញ់វិនាសហិនហោចទៅ »។

ព្រះរាជាទ្រុបទឡើងទឹកព្រះភក្ត្រច្រាល ដោយលោហិត ទ្រង់ត្រាស់ថា «យើងសុំធ្វើពាក្យប្ដេជ្ញាប្រកាសទុកក្នុងទីនេះថា បើអ្នកឯងមិនបានចំណែកព្រះនគរដោយស្រួលបួលទេ យើងនឹងជួយឲ្យទាល់តែបានដោយកម្លាំងសស្ត្រាវុធ»។

ខណៈនោះ អ្នកភ្នាក់ងារមុខក្រសួងនាំទូតានុទូត ចូលទៅគាល់ទូតទាំងនោះចូលក្រាបនៅចំពោះព្រះភក្ត្រក្រាបទូលថា «ខត្តិយាធិបតីដ៏ជាម្ចាស់របស់ទូលព្រះបង្គំជាខ្ញុំ ត្រាស់បញ្ជាឲ្យនាំព័ត៌មានដ៏ជាមង្គលមកក្រាបទូលព្រះអង្គឲ្យទ្រង់ជ្រាប ដ្បិតព្រះរាជាមានព្រះរាជហឫទ័យសោមនស្សណាស់ ត្រង់ការបានឃើញសេចក្ដីរួបរួមគ្នា

រវាងរាជត្រកូលទាំង ២ គឺ បណ្ឌុ និង បញ្ចាល ប៉ុន្តែព្រះរាជាក៏ជាប្រធាននៃកុរុរដ្ឋមានព្រះរាជហឫទ័យ បំណងនឹងឃើញវិមលភក្ត្រព្រះភាគិនេយ្យទាំង ៥ អង្គ ព្រះរាជជិនីសោតទៀត ក៏ចង់យល់ភក្ត្រយុវតីស្ត្រីសុណិសាណាស់ ខាងពួកប្រជាជនរៀបត្រៀបព្រមគ្នាស្រេចហើយបម្រុងចាំទទួលស្ដេច»។

ព្រះរាជាទ្រុបទ មិនសព្វព្រះរាជហឫទ័យក្នុងរឿងដែលបាណ្ឌពក្សត្រិយ៍នឹងនាំគ្នាត្រឡប់ទៅក្រុងហាស្តិនបុរវិញទេ ប៉ុន្តែនឹងទ្រង់ហាមឃាត់ហាក់ដូចជាការមិនគួរ ក្នុងទីបំផុតក៏ទ្រង់អនុញ្ញាតតាមសុំ។

បាណ្ឌពក្សត្រិយ៍ព្រមដោយព្រះជននី និងនាងទ្រៅបទីក៏រៀបចំរាជដំណើរ ស្ដេចដើរផ្លូវទៅថ្កានក្រុងហាស្តិនបុរ មានសេនាទាហាននិងរាជបរិពារជាក្បួនហែហម និងមានភ្លេងត្រែ ស័ង្ខ តូរ្យតន្ត្រីប្រគំសូរស័ព្ទទ្រហឹងអឹងអាប់ទៅតាមមគ្គវិថី ។ កាលយាងដល់ក្រុងហាស្តិនបុរហើយ មន្ត្រីខុំរាជការជាន់ខ្ពស់ ចេញចាំទទួលនៅត្រង់ទ្វារព្រះនគរ ។ រាស្ត្រនិករទាំងពួង ក៏ជ្រួលជ្រើមបបួលគ្នាមកទទួលស្ដេចជាទីសម្លាញ់របស់គេ ដោយបីតិដ៏មានកម្លាំង សឹងពុំអាចនឹងទប់ជើងឲ្យនៅនឹងបានឡើយ ។ លុះបានឮសូរកាំភ្លើង ទឹង ! ទឹង ! ដែលគេបាញ់ថ្វាយគំនាប់ខ្ទ័រទាំងពសុធា អ្នកនគរក៏សន្និដ្ឋានថា ព្រះប្រិយក្សត្រិយ៍របស់គេ បានយាងចូលមកដល់ក្នុងខេត្រព្រះនគរហើយ ។



សេចក្ដីរីករាយរបស់រាស្ត្រទប់ជើងមិននឹង ។ បណ្ដាមនុស្សប្រុសស្រីចាស់ក្មេង ធំតូច ស្រោកស្រហូរហែចេញមកដើម្បីឃើញបាណ្ឌពក្សត្រិយ៍ ។ នាទីព្រះរាជវាំង និងតាមផ្លូវថ្នល់គេដោតរាជវ័តឆត្រ ទង់ព្រោងព្រាយ, នៅមាត់ទ្វារផ្ទះនីមួយ ៗ ក៏សុទ្ធតែប្រដាប់ដោយគ្រឿងសម្ដែងសេចក្ដីបដិសណ្ឋារៈត្រេកអរទទួល និងជាទីប្រដាប់កិត្តិយសនៃខត្តិយរាជ ។ លុះបាណ្ឌពក្សត្រិយ៍ចូលដល់ទីគាល់ហើយ ព្រះបាទធ្ឫតរាស្ត្រ ក៏ស្ដេចចុះចាករាជបល្ល័ង្កតម្រង់មកឱបក្សួយរាល់អង្គតាមលំដាប់ ។ បាណ្ឌពក្សត្រិយ៍ក៏ក្រាបទាបព្រះបាទយុគល ទទួលព្រះពរ ។ ព្រះរាជិនី និងពួកនារីដែលមានបណ្ដាស័ក្តិខ្ពស់ក្នុងរាជដំណាក់ក៏ដូចគ្នានាំគ្នាទៅទទួលនាងទ្រៅបទី ។ នាងទ្រៅបទីក៏ក្រាបចុះទៀបព្រះបាទសម្ដែងសេចក្ដីគោរព តាមរបៀបសុភាពស្ត្រី មើលទៅកិរិយាមារយាទ និងរូបឆោមរបស់នាងជាទីត្រូវព្រះហឫទ័យនៃព្រះរាជវង្សានុវង្សក្សត្រីជាយ៉ាងក្រៃលែង ។ ពួកប្រយូរវង្សគ្រប់ ៗ អង្គក៏ស្រឡាញ់ពេញហឫទ័យ នឹងសរសើរគុណសម្បទរបស់នាងជាអនេកប្រការ ។

ការផ្សះផ្សាររវាងព្រះញាតិ ដែលឃ្លាតចាកគ្នាទៅយូរហើយបានសះជាព្រមព្រៀងគ្នាឡើងវិញដោយប្រការដូច្នេះ ។ មធុរកថារបស់ព្រះបាទធ្ឫតរាស្ត្រ ក៏ត្រាស់ប្រលោមលួងលោមឲ្យសាមគ្គីនឹងគ្នាទៅវិញជាច្រើនប្រការ ទោះបីមិនសូវស្និទ្ធស្នាលនឹងគ្នាដូចអំពីដើមក៏អង្គីក្តី ទ្រង់ប្រាស្រ័យនឹងយុធិស្ឋិរជាក្សួយច្បងថា «សេចក្ដីអរិ-

ចិត្តរវាងក្មួយ និងមាវេលានេះ ឈ្មោះថាលែងមានទៀតហើយ តទៅខាងមុខ សូមឲ្យមេត្រីភាពរវាងត្រកូល កុរុ និង បណ្ឌុ គប្បីមានទៅវិញទៅមក ដែលជាព្រះញាតិជីដូនមួយនឹងគ្នា មាសុខចិត្តបែងចែកដែនដីឲ្យក្មួយពាក់កណ្ដាល ក្មួយនឹងតាំងរាជធានីឡើងថ្មីនៅខាណ្ឌវបថ ឬនៅទីដទៃទៀតក៏បាន ហើយចូរគ្រប់គ្រងអាណាចក្ររបស់ក្មួយ ឲ្យជាសុខសម្រាន្ត ភិយ្យោយសចុះ »។

អាស្រ័យហេតុនេះ រាជអាណាចក្រហាស្តិនបុរ ទើបត្រូវញែកចែកជា ២ ភាគ ទុរយោធន៍ រើសយកខែត្រផ្សេងក្នុងទិសបូពិ ដែលជាទីសម្បូរទៅដោយផលាផលជាសិទ្ធិរបស់ខ្លួន ។ យុធិស្ឋិរបានភាគខាងលើដែលជាទីអរញ្ញប្រទេស ត្រូវកាប់គាស់រានដីសាងជារាជធានីទីក្រុងថ្មីឡើង ។